# សង្កេតការណ៍ ១

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម



# ខៀវ សំផន ហៅ សមមិត្ត ហែម

ខែវិច្ឆិកា ឆ្នាំ២០១១

## មាតិកា


សេចក្តីផ្តើម ១
សវនាការបឋម ២
ការលើកលែងទោស ៥
ការរំលោភលើអនុសញ្ញា ៨
អាជ្ញាយុកាលបទល្មើស ៩
សក្ខីកម្មផ្ទាល់មាត់ ១៣
បញ្ហាផ្សេង ១៦
សន្និដ្ឋាន ១៨



ក្រុមសង្កេតការណ៍ :
គីម ម៉ារីយ៉ាន, ឌី សុជាតា,
លឹម ជ័យទត្ត និង ចាន ប្រាថ្នា



អ្នកទោសនៅមន្ទីរស-២១ (រូបថត ៖ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង)

# ការចាប់ផ្ដើមជាប្រវត្តិសាស្ត្រនៃការជំនុំជម្រះ សំណុំរឿងលេខ ០០២ : សវនាការបឋម

**ថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ២០១១**

*ដោយ គីម ម៉ារីយ៉ាន, ឌី សុជាតា, លឹម ជ័យទត្ត និង ចាន ប្រាថ្នា*

## ១) សេចក្ដីផ្ដើម

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលស្គាល់ជាទូទៅថាជាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានបើកសវនាការបឋមលើសំណុំរឿងលេខ ០០២ ពីថ្ងៃទី២៧ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ប្រឆាំងនឹងជនជាប់ចោទចំនួនបួនរូប ។ ជនជាប់ចោទទីមួយឈ្មោះ នួន ជា មានតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ជាសមាជិកគណៈ



**និស្សិតសាកលវិទ្យាល័យកំពុងតម្រង់ជួរចូលសាលសវនា ឆ្នាំ២០១១**

កម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា និងរួមទាំងតួនាទីជាប្រធានសភាប្រជាជននៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនជាប់ចោទទីពីរឈ្មោះ អៀង សារី មានតួនាទីជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីសកម្ពុជា ។ ជនជាប់ចោទទីបីឈ្មោះ អៀង ធីរិទ្ធ មានតួនាទីជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំណែកជនជាប់ចោទទីបួនមានឈ្មោះ ខៀវ សំផន មានតួនាទីជាគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

សវនាការបឋម គឺជាសវនាការមួយដែលធ្វើឡើងនៅមុនពេលចាប់ផ្ដើមសវនាការអង្គសេចក្ដីនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ សវនាការបឋមនេះមិនមាននៅក្នុងនីតិវិធីរបស់តុលាការក្នុងស្រុករបស់កម្ពុជាទេនៅក្នុងរឿងព្រហ្មទណ្ឌ ។ សវនាការបឋមនេះធ្វើឡើង ដើម្បីឲ្យគូភាគីដែលរួមមានសហព្រះរាជអាជ្ញា សហមេធាវីការពារក្ដីឲ្យជនជាប់ចោទ និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើការឆ្លើយតបទៅលើបញ្ហាផ្លូវច្បាប់មួយចំនួនដែលនឹងត្រូវលើកយកមកពិភាក្សានៅមុនពេលសវនាការអង្គសេចក្ដីចាប់ផ្ដើម ។ បញ្ហាមួយចំនួនត្រូវបានលើកយកមកពិភាក្សានៅក្នុងសវនាការបឋមកាលពីថ្ងៃ ទី២៧ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ហើយបញ្ហាទាំងនេះរួមមាន ៖

◆ ការពិភាក្សាលើអញ្ញត្រកម្មនៃគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ។ បញ្ហានេះត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្ដីរបស់ជនជាប់ចោទ អៀង សារី ដោយសារតែជនជាប់ចោទនេះត្រូវបានតុលាការប្រជាជនបដិវត្តធ្វើការកាត់ទោសម្ដងរួចមកហើយ កាលពីឆ្នាំ១៩៧៩ ។

◆ អញ្ញត្រកម្មទាក់ទងនឹងការលើកលែងទោស និងអនុគ្រោះទោសដែលបានផ្ដល់ឲ្យជនជាប់ចោទ អៀង សារី ដោយព្រះមហាក្សត្រ ព្រះរាជាណាចក្រកម្ពុជាកាលពីឆ្នាំ១៩៩៦ ។

◆ អញ្ញត្រកម្មទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើសរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩

◆ អញ្ញត្រកម្មទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើសជាតិ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។

◆ ការពិភាក្សាលើបញ្ហានានាដែលទាក់ទងទៅនឹងសំណង ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

◆ ការបង្ហាញបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី

គោលបំណងក្នុងការលើកបញ្ហាទាំងអស់ខាងលើមកធ្វើការជជែកដេញដោលនៅក្នុងសវនាការបឋមនេះ គឺដើម្បីដោះស្រាយនូវរាល់បញ្ហាដែលលើកឡើងដោយគូភាគី និងដើម្បីអាចឈានចូលទៅដល់ដំណើរសវនាការលើអង្គសេចក្តីបានលឿនតែម្តង ។ ខាងក្រោមនេះគឺរបាយការណ៍សង្ខេបមួយធ្វើឡើងដោយគម្រោងសង្កេតមើលដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងអំឡុងពេលនៃសវនាការបឋមនៅក្នុងសំណុំរឿងលេខ០០២ ។ បញ្ហាទាំងឡាយដែលត្រូវបានលើកមកពិភាក្សាដេញដោលនៅក្នុងសវនាការបឋមនេះមិនទាន់ត្រូវបានសម្រេចដោយអង្គជំនុំជម្រះនៅឡើយទេ ។

## ២) សវនាការបឋមពាក់ព័ន្ធនឹង «គោលការណ៍មិនអាចកាត់ទោសពីរដងលើបទល្មើសតែមួយ»

ការបើកសវនាការបឋមពាក់ព័ន្ធនឹងគោលការណ៍មិនអាចកាត់ទោសពីរដងលើបទល្មើសតែមួយ គឺផ្តោតតែទៅលើជនជាប់ចោទ អៀង សារី តែម្នាក់ប៉ុណ្ណោះ ។ កាលពីឆ្នាំ១៩៧៩ ជនជាប់ចោទ អៀង សារី ត្រូវបាន "តុលាការប្រជាជនបដិវត្តកម្ពុជា" កាត់ទោសប្រហារជីវិត និងដកហូតទ្រព្យសម្បត្តិទាំងអស់ ។ តុលាការប្រជាជនបដិវត្តកម្ពុជាបានជំនុំជម្រះទោស ប៉ុល ពត និង អៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងនៅអំឡុងពេលកាន់អំណាច នៅចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ។ នៅក្នុងសវនាការបឋមនេះ អង្គជំនុំជម្រះបានផ្តល់សិទ្ធិឲ្យភាគីទាំងអស់អាចលើកឡើងនូវអំណះអំណាងដែលពាក់ព័ន្ធទៅនឹងគោលការណ៍មិនអាចកាត់ទោសពីរដងលើបទល្មើសតែមួយនេះទៅតាមរយៈពេលដែលបានកំណត់នៅក្នុងរបៀបវារៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានគ្រោងទុក ។ ខាងក្រោមនេះគឺគ្រាន់តែរបាយការណ៍នៃការសួរដេញដោលនេះប៉ុណ្ណោះ ។

### ក) សហមេធាវីការពារជនជាប់ចោទ អៀង សារី

សហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី បានលើកឡើងនូវអំណះអំណាងពាក់ព័ន្ធទៅនឹងគោលការណ៍មិនអាចកាត់ទោសពីរដងចំពោះបទល្មើសតែមួយដូចខាងក្រោមនេះ ៖

ទី១) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលទើបតែបង្កើតឡើងនេះមិនអាចធ្វើការកាត់ទោសចំពោះជនជាប់ចោទ អៀង សារី សាជាថ្មីម្តងទៀតឡើយ ដោយហេតុថាជនជាប់ចោទនេះធ្លាប់ត្រូវបានតុលាការប្រជាជនបដិវត្តធ្លាប់កាត់ទោសម្តងរួចហើយកាលពីឆ្នាំ១៩៧៩ ដែលនៅពេលនោះ អៀង សារី ត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទល្មើសផ្សេងៗទៀត ។ ដោយយោងទៅលើគោលការណ៍ "អាជ្ញាអស់ជំនុំ" ដែលមានចែងក្នុងមាត្រា៧ និងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ។ លើសពីនេះទៅទៀតភាគីសហមេធាវីរបស់ជនជាប់ចោទ អៀង សារី បានធ្វើការបកស្រាយទៅលើមាត្រា១២នៃក្រមនេះថា ការដែលមិនអាចផ្តន្ទាទោសពីរដងចំពោះបទល្មើសតែមួយ គឺមានអានុភាពមិនត្រឹមតែចំពោះបុគ្គលដែលតុលាការសម្រេចដោះលែងជាស្ថាពរប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងមានអានុភាពទៅលើបុគ្គលដែលតុលាការកាត់ទោសឲ្យមានពិរុទ្ធភាពរួចហើយថែមទៀតផង ។ អត្ថន័យនៅត្រង់ចំណុចនេះ ខាងសហមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី ចង់បង្ហាញថា មិនថាជនជាប់ចោទណាក៏ដោយ ឲ្យតែតុលាការចេញសេចក្តីសម្រេចដោះលែងឬកាត់ទោសឲ្យជាប់ពិរុទ្ធ ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរ គឺមានន័យថាជននោះត្រូវបានតុលាការបានកាត់ទោសរួចហើយ ។ ដូច្នេះតុលាការមិនអាចនាំយកជនជាប់ចោទដែលត្រូវបានកាត់ទោសរួចហើយនេះមកកាត់ទោសសាជាថ្មីម្តងទៀតបានឡើយ ព្រោះការធ្វើបែបនេះបានរំលោភលើសិទ្ធិរបស់ជនជាប់ចោទ និងទៅលើច្បាប់ជាតិនិងអន្តរជាតិ ។

ទី២) តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវអនុវត្តតាមមាត្រា១៤ វាក្យខណ្ឌ៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានចែងថា "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសាជាថ្មីឡើយចំពោះបទល្មើសដែលមានផ្តន្ទាទោសជាស្ថាពរ ឬមានការលើកលែងទោសស្រប

តាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ» ។ យោងទៅតាមមាត្រាខាងលើនេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មិនអាចធ្វើការចោទប្រកាន់ជនជាប់ចោទ អៀង សារី ជាលើកទី២បានឡើយ ។

ទី៣) តុលាការប្រជាជនបដិវត្តកម្ពុជាដែលត្រូវបានបង្កើតក្នុងឆ្នាំ១៩៧៩ គឺពិតជាមានអំណាចពេញលេញក្នុងការកាត់ទោស អៀង សារី ហើយការផ្តន្ទាទោសប្រហារជីវិតនៅពេលនោះនឹងប្រាកដជាត្រូវបានគេយកមកអនុវត្តភ្លាម ប្រសិនបើគាត់មានវត្តមានក្នុងសវនាការ នៅពេលនោះ ។ ដូច្នេះគេមិនអាចនិយាយថាមិនមានការកាត់ទោសពេញលេញចំពោះ អៀង សារី ដោយតុលាការប្រជាជនបដិវត្តកម្ពុជា កាលពីឆ្នាំ១៩៧៩ នោះទេ ។

ទី៤) តុលាការប្រជាជនបដិវត្តកម្ពុជាកាលពីឆ្នាំ១៩៧៩ គឺជាតុលាការរបស់កម្ពុជា ហើយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ ក៏ជាតុលាការដែលបង្កើតដោយច្បាប់កម្ពុជាដែរ ។ ដូច្នេះ តុលាការរបស់កម្ពុជាពីរមិនអាចធ្វើការកាត់ទោស អៀង សារី លើបទល្មើសតែមួយបានទេ ។

ទី៥) សាលក្រមរបស់តុលាការប្រជាជនបដិវត្តកម្ពុជា ឆ្នាំ១៩៧៩ គឺជាសាលក្រមដែលនៅមានសុពលភាពនៅឡើយ ដោយសារថា ចាប់ពីពេលចេញសាលក្រមរហូតមកដល់ពេលបច្ចុប្បន្ន មិនមានបុគ្គលណាម្នាក់អះអាងថា សាលក្រមនោះគ្មានសុពលភាពនោះទេ ។ ខាងមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី អះអាងថា ចំពោះការបង្កើតតុលាការឆ្នាំ១៩៧៩ ដោយក្រឹត្យច្បាប់ គឺមិនមែនជាបញ្ហាទេ ដោយសារនៅពេលនោះប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលអន្តរកាល ។

ទី៦) ចំពោះធាតុផ្សំបទល្មើសដែលជាបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលបានជំនុំជម្រះដោយតុលាការប្រជាជនបដិវត្តកម្ពុជាឆ្នាំ១៩៧៩នេះ គឺមានលក្ខណៈស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងបទចោទប្រកាន់ទាំងអស់នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២នាពេលបច្ចុប្បន្ន ។

ជាសរុបមក មេធាវីការពារក្តីឲ្យ អៀង សារី បានលើកឡើងថា ដោយអនុលោមតាមគោលការណ៍មិនអាចកាត់ទោសពីរដងចំពោះបទល្មើសតែមួយដែលមានចែងក្នុងមាត្រា៧ និងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ និងមាត្រា១៤ វាក្យខណ្ឌ៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនធ្វើការកាត់ទោស អៀង សារី ជាលើកទីពីរចំពោះឧក្រិដ្ឋកម្មដដែលបានទៀតទេ ។

## ១) ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា

ក្រោយពីការលើកឡើងនូវអំណះអំណាងរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី សហព្រះរាជអាជ្ញាបានធ្វើការឆ្លើយតបមួយចំនួនចំពោះអ្វីដែលមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី បានលើកឡើងដូចខាងក្រោម ៖

ទី១) ចំពោះគោលការណ៍មិនអាចធ្វើការជំនុំជម្រះពីរដងចំពោះបទល្មើសតែមួយ ដែលមានចែងក្នុងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ គឺអាចអនុវត្តបានតែទៅលើបុគ្គលណាដែលត្រូវបានតុលាការសម្រេចធ្វើការដោះលែងនិងនៅពេលដែលសាលក្រមដោះលែងនេះចូលជាស្ថាពរប៉ុណ្ណោះ ។ បុគ្គលដែលត្រូវបានតុលាការកាត់ទោសឲ្យមានពិរុទ្ធភាពហើយ គឺមិនអាចទទួលបានផលប្រយោជន៍ពីគោលការណ៍ «មិនអាចជំនុំជម្រះទោសពីរដង» នេះទេ ។

ទី២) ចំពោះការកាត់ទោសជនជាប់ចោទ អៀង សារី នៅឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តកម្ពុជានោះ គឺជាការកាត់ទោសដោយមិនមានភាពត្រឹមត្រូវ និងយុត្តិធម៌ ដែលមិនអាចទទួលយកបានឡើយ ។ ជារួមការកាត់ទោសដោយតុលាការប្រជាជនបដិវត្តកម្ពុជានៅពេលនោះ គឺមិនបំពេញបានសូម្បីតែបទដ្ឋានទាបបំផុតនៃការជំនុំជម្រះទោសដោយត្រឹមត្រូវយុត្តិធម៌ ។ សហព្រះរាជអាជ្ញាបានផ្តល់នូវហេតុផលមួយចំនួនដូចជា ៖

◆ ការកាត់ទោសជនជាប់ចោទ អៀង សារី ពីបទប្រល័យពូជសាសន៍ដែលជាបទល្មើសធ្ងន់ធ្ងរមួយ ប៉ុន្តែតុលាការប្រជាជនបដិវត្តកាលពីឆ្នាំ១៩៧៩ បានប្រើរយៈពេលក្នុងការបើកសវនាការកាត់ទោស និងចេញសេចក្តីសម្រេចក្នុងរយៈពេលត្រឹមតែ៥ថ្ងៃប៉ុណ្ណោះ ។ ហើយម្យ៉ាងវិញទៀត នៅពេលនោះមិនមានការបើកការស៊ើបអង្កេតច្បាស់លាស់ណាមួយឡើយ ហើយក៏គ្មានការស៊ើបអង្កេតរកភស្តុតាងដោះបន្ទុកសម្រាប់ជនជាប់ចោទដែរ ។ ចៅក្រមធ្វើការស៊ើបអង្កេតរកតែភស្តុតាងសម្រាប់តែដាក់បន្ទុក

ទៅលើ អៀង សារី ប៉ុណ្ណោះ ។ និយាយរួមការការកាត់ក្តីនេះ គឺធ្វើឡើងដើម្បីរំសាយកំហឹងដែលកើតមានពីរបបកម្ពុជាប្រជាធិបតេយ្យតែប៉ុណ្ណោះ ។

◆ សិទ្ធិរបស់ជនជាប់ចោទមិនត្រូវបានធានាដោយមាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ ។ ដោយសារនៅពេលនោះ អៀង សារី ត្រូវបានតុលាការប្រជាជនបដិវត្តកម្ពុជា សម្រេចសេចក្តីដោយកំបាំងមុខ និងបិទផ្លូវតវ៉ា ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺតុលាការនៅពេលនោះមានតែមួយថ្នាក់ប៉ុណ្ណោះ គ្មានសាលាឧទ្ធរណ៍សម្រាប់ឲ្យជនជាប់ចោទអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់តុលាការប្រជាជនបដិវត្តកម្ពុជានេះបានឡើយ ។

◆ តុលាការឆ្នាំ១៩៧៩នេះ គឺមិនមានឯករាជ្យ តម្លាភាព និងយុត្តិធម៌ទេ ។ ដូច្នេះការសេចក្តីសម្រេចរបស់តុលាការមួយនេះ គឺគួរតែត្រូវបានចាត់ទុកជាមោឃៈ ដោយសារចៅក្រមមួយចំនួន គឺជាសមាជិករបស់រដ្ឋាភិបាលនាសម័យនោះ ។ ចៅក្រម កែវ ចិន្តា ជាសមាជិករបស់រដ្ឋាភិបាល ត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធានតុលាការនេះ និងបានធ្វើសេចក្តីថ្លែងការណ៍នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៩ ដោយបញ្ជាក់ថា "វាច្បាស់ណាស់ដែលថា អៀង សារី បានប្រព្រឹត្តិអំពើអមនុស្សធម៌នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងជាមេដឹកនាំប្រព្រឹត្តអំពើឧក្រិដ្ឋកម្មជាច្រើន ដូច្នេះជននេះនឹងត្រូវបានគេកាត់ទោស" ។ ក្នុងករណីនេះ អៀង សារី ត្រូវបានគេសន្មតទុកជាមុនថាមានទោស ដោយប្រធានតុលាការតាំងនៅមុនពេលកាត់ទោសគាត់ម៉្លេះ ។ ចំណែកមេធាវីការពារក្តីរបស់ អៀង សារី ដែលត្រូវបានជ្រើសតាំងដោយប្រធានតុលាការបានធ្វើសកម្មភាពដោយលម្អៀង និងមិនត្រឹមត្រូវចំពោះកូនក្តីរបស់ខ្លួន ។ ពេលនោះ មេធាវីរបស់ អៀង សារី បានទទួលស្គាល់ថា កូនក្តីរបស់ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសមែន ។ អ្វីដែលត្រូវមើលឃើញជាងនេះទៅទៀតនោះ គឺតុលាការប្រជាជនបដិវត្តកម្ពុជាឆ្នាំ១៩៧៩នេះត្រូវបានបង្កើតដោយក្រឹត្យច្បាប់ដែលចេញដោយរដ្ឋាភិបាលនៅពេលនោះទៅវិញ ។ ជាគោលការណ៍ច្បាប់ តុលាការត្រូវតែបង្កើតដោយច្បាប់ដែលអនុម័តដោយសភា ។

សហព្រះរាជអាជ្ញាបានអះអាងថា តាមរយៈមូលហេតុខាងលើនេះ ការកាត់សេចក្តីរបស់តុលាការប្រជាជនបដិវត្តកម្ពុជាមិនអាចទទួលយកបានទេ និងត្រូវទុកជាមោឃភាព ។ ដូច្នេះសហព្រះរាជអាជ្ញាធ្វើការស្នើសុំឲ្យអង្គជំនុំជម្រះធ្វើការបដិសេធចោលទាំងស្រុងនូវការលើកឡើងរបស់មេធាវីជនជាប់ចោទ អៀង សារី ។

### ក) ការឆ្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីតំណាងផលប្រយោជន៍ជនរងគ្រោះ ក៏បានធ្វើសេចក្តីឆ្លើយតបបន្ថែមទៅលើគោលការណ៍ មិនអាចកាត់ទោសពីរដងចំពោះបទល្មើតែមួយប្រឆាំងតបទៅនឹងអ្វីដែលត្រូវបានលើកឡើងដោយសហមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី ។ សហមេធាវីនាំមុខបានផ្តល់នូវអំណះអំណាងមួយចំនួនដូចខាងក្រោម ៈ

ទី១) ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលមានលក្ខណៈអន្តរជាតិ បើយោងទៅតាមច្បាប់អន្តរជាតិ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនគួរទទួលយកគោលការណ៍គ្មានការកាត់ទោសពីរដងចំពោះអំពើល្មើសតែមួយមកអនុវត្តចំពោះករណីរបស់ជនជាប់ចោទ អៀង សារី ឡើយ ។ បើទោះបីជា អៀង សារី ត្រូវបានកាត់ទោសម្តងរួចហើយក៏ដោយ ក៏ការកាត់ទោសនេះមិនមែនជាឧបសគ្គរារាំងមិនឲ្យធ្វើការចោទប្រកាន់ អៀង សារី នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ ។ ជាក់ស្តែង មានយុត្តិសាស្ត្រមួយនៅក្នុងតុលាការប្រទេសបារាំងឆ្នាំ១៩៤៦ ដែលមានជនជាប់ចោទឈ្មោះ ទុយវីយេ ដែលត្រូវបានតុលាការបានផ្តន្ទាទោសប្រហារជីវិត ហើយក្រោយមកជននោះត្រូវទទួលបានការលើកលែងទោសពីសំណាក់ប្រធានាធិបតី ។ ក៏ប៉ុន្តែដោយសារមានការតវ៉ាយ៉ាងខ្លាំងពីមហាជន ទើបតុលាការបានធ្វើការកាត់ទោសបុគ្គលនោះម្តងទៀត ដោយមានការកំណត់អង្គហេតុជាថ្មីពីបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ទី២) ការកាត់ទោសដោយតុលាការឆ្នាំ១៩៧៩គឺមិនបានឆ្លើយតបទៅនឹងសិទ្ធិទទួលបានសំណងជំងឺចិត្តរបស់ជនរងគ្រោះឡើយ ។ ជាគោលការណ៍បុគ្គលម្នាក់ៗមានសិទ្ធិទទួលបានសំណងជំងឺចិត្តដែលខ្លួនបានទទួលរង ។

ទី៣) តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាតុលាការអន្តរជាតិមួយ ដូច្នេះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវគោរពច្បាប់ និងកាតព្វកិច្ចអន្តរជាតិក្នុងការកាត់ទោសឧក្រិដ្ឋកម្ម

ធ្ងន់ធ្ងរដែលរំលោភលើច្បាប់ និងទំនៀមទំលាប់អន្តរជាតិ ។ ម្យ៉ាងវិញទៀត ការមិនព្រមកាត់ទោស អៀង សារី គឺមានន័យថាតុលាការកំពុងតែបង្កើននិងទទួលយកវប្បធម៌និទ្ទណ្ឌភាពដោយស្ងៀមស្ងាត់ ។ ដូច្នេះមិនមានឧបសគ្គរារាំងណាមួយក្នុងការនាំយកជនជាប់ចោទ អៀង សារី មកធ្វើការចោទប្រកាន់ និងជំនុំជម្រះទោសនៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។

## ៣) អញ្ញត្រកម្មស្តីពីការលើកលែងទោស និងការអនុគ្រោះទោស

ការលើកឡើងអំពីអញ្ញត្រកម្មស្តីពីការលើកលែងទោសនិងការអនុគ្រោះទោសត្រូវបានលើកយកមកពិភាក្សាដេញដោលនៅក្នុងថ្ងៃទី២នៃសវនាការបឋម ។

កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ ព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅពេលនោះបានឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យមួយលើកលែងទោស និងអនុគ្រោះទោសដល់ អៀង សារី ។ ព្រះរាជក្រឹត្យចំនួនពីរទំព័រនេះមានតែបីមាត្រាខ្លីៗប៉ុណ្ណោះ ។ មាត្រាទាំងបីនេះមានសេចក្តីទាំងស្រុងដូចខាងក្រោមនេះ ៖

“មាត្រា១ ៖ ត្រូវបានលើកលែងទោសឲ្យលោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានផ្តន្ទាទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ និងចំពោះទោសដែលបានកំណត់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤ ។

មាត្រា២ ៖ ព្រះរាជក្រិត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា៣ ៖ ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ត្រូវអនុវត្តព្រះរាជក្រិត្យនេះ ឲ្យសម្រេចជាស្ថាពរ ។”

### ក) សហមេធាវីការពារក្តីជនជាប់ចោទ អៀង សារី

ចំពោះអញ្ញត្រកម្មនេះ ភាគីមេធាវីការពារក្តីរបស់ជនជាប់ចោទ អៀង សារី ដែលមានទាំងសហមេធាវីជាតិនិងអន្តរជាតិបានលើកឡើងបីចំណុចសំខាន់ៗដើម្បីការពារកូនក្តីរបស់ខ្លួន ។

ទី១) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានសមត្ថកិច្ចត្រួតពិនិត្យតែទៅលើអានុភាពព្រះរាជក្រឹត្យប៉ុណ្ណោះ ប៉ុន្តែមិនមានសមត្ថកិច្ចកំណត់លើសុពលភាពរបស់ព្រះរាជក្រឹត្យនោះទេ ។ ជាការពិត រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរព និងបកស្រាយរដ្ឋធម្មនុញ្ញនិងច្បាប់ដែលរដ្ឋសភាបានអនុម័ត ។ យ៉ាងណាមិញ សហមេធាវី



ចៅក្រមអន្តរជាតិ ស៊ីលវៀ ខាត់វ៉ាយ និងចៅក្រមជាតិ និល ណុន (ប្រធានអង្គជំនុំជម្រះសាលាដំបូង)

ការពារក្តីឲ្យ អៀង សារី បានលើកឡើងថា អ្នកដែលមានសមត្ថកិច្ចកំណត់ពីសុពលភាពព្រះរាជក្រឹត្យ គឺក្រុមប្រឹក្សាធម្មនុញ្ញទៅវិញទេ ។ មេធាវីការពារក្តី អាង ឧត្តម បានបន្តទៀតថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនជាតុលាការធម្មនុញ្ញឡើយ ។ ច្បាប់បង្កើតតុលាការនេះក៏មិនបានផ្តល់អំណាចណាមួយឲ្យបកស្រាយលើព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រនោះដែរ ។

ទី២) ព្រះរាជក្រឹត្យដែលបានចេញកាលពីឆ្នាំ១៩៩៦មានសុពលភាពចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មេធាវីរូបនេះបានបន្តទៀតថា ព្រះរាជក្រឹត្យលើកលែងទោសនេះគឺជាលក្ខខណ្ឌមួយដើម្បីធ្វើឲ្យ អៀង សារី ព្រមធ្វើសមាហរណកម្ម

ចុះចូលជាមួយរាជរដ្ឋាភិបាល ។ ដើម្បីធ្វើសមាហរណកម្មនេះ អៀង សារី បានចរចាជាមួយនឹងនាយករដ្ឋមន្ត្រីទីមួយសម្តេច នរោត្តម រណឫទ្ធិ និងនាយករដ្ឋមន្ត្រីទីពីរ ហ៊ុន សែន ។ ការធ្វើសមាហរណកម្មនេះ គឺដើម្បីបញ្ចប់សង្គ្រាមស៊ីវិលដែលបង្កឡើងដោយខ្មែរក្រហម ។ មេធាវីបន្តថា អៀង សារី នឹងមិនយល់ព្រមធ្វើសមាហរណកម្មទេ ប្រសិនបើគាត់មិនបានទទួលនូវការលើកលែងទោសដើម្បីឲ្យគាត់បានរួចផុតពីការចោទប្រកាន់នានានៅពេលអនាគត ។ សហមេធាវីអន្តរជាតិ មីកាអែល កាណាវ៉ាស ការពារក្តីឲ្យ អៀង សារី បានលើកឧទាហរណ៍មួយថា នៅប្រទេសលីប៊ី មានប្រទេសជាច្រើនដែលកំពុងតែព្យាយាមចរចាដើម្បីឲ្យហ្កាដាហ្វីចុះចេញពីដំណែងដើម្បីស្វែងរកការផ្សះផ្សារជាតិនិងទប់ស្កាត់ការបង្ហូរឈាម ដោយប្តូរមកវិញនូវការផ្តល់ទីកន្លែងឲ្យលោក ហ្កាដាហ្វីជ្រកកោន ។ ស្របជាមួយគ្នានោះដើម្បីឲ្យ អៀង សារី យល់ព្រមចុះចូលជាមួយនឹងរាជរដ្ឋាភិបាល ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ បានចេញព្រះរាជក្រឹត្យមួយ ស្តីពីការលើកលែងទោសឲ្យ អៀង សារី តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រីទាំងពីរ និងតាមការអនុញ្ញាតដោយមាត្រា២៧ នៃរដ្ឋធម្មនុញ្ញកម្ពុជា ។ ដោយព្រះរាជក្រឹត្យនេះត្រូវបានអនុម័តដោយសំឡេងពីរភាគបីនៃរដ្ឋសភា ។ សហមេធាវីជាតិបន្តទៀតថា ប្រសិនបើពេលនោះមិនមានការធ្វើសមាហរណកម្មរបស់ អៀង សារី ទេ ម្ល៉េះសង្គ្រាមស៊ីវិលប្រហែលជានឹងកំពុងតែបន្តញាំញីប្រទេសកម្ពុជារហូតដល់បច្ចុប្បន្នដងក៏អាចថាបាន ។

ទី៣) វិសាលភាពនៃការលើកលែងទោសអាចធ្វើឲ្យ អៀង សារី រួចផុតពីកាចោទប្រកាន់នៅចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្នុងការដេញដោលនៅក្នុងអង្គសវនាការ សហមេធាវីបានលើកឡើងទៀតថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចកាត់ទោស អៀង សារី បានទេ ដោយសារតែព្រះរាជក្រឹត្យលើកលែងទោសនោះនៅមានសុពលភាពនៅឡើយ ។

### ១) សហព្រះរាជអាជ្ញា

ដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្តីរបស់ អៀង សារី ភាគីសហព្រះរាជអាជ្ញាបានលើកឡើងនូវ២ចំណុចសំខាន់ៗចំពោះអញ្ញត្រកម្មនេះ ។

ទី១) ព្រះរាជក្រឹត្យស្ថិតក្នុងវិសាលភាពដាក់លាក់ ។ ចំពោះវិសាលភាពជាក់លាក់នៃព្រះរាជក្រឹត្យនេះ សហព្រះរាជអាជ្ញារងជាតិបានបញ្ជាក់ថា វិសាលភាពនេះត្រូវបានបង្ហាញឡើងតាមរយៈ អត្ថន័យនៅក្នុងមាត្រាដែលចែងនៅក្នុងព្រះរាជក្រឹត្យ ។

ព្រះរាជអាជ្ញាបានបន្តថា ពាក្យថាការអនុគ្រោះទោសឬភាសាអង់គ្លេសហៅថា "រ៉ូយ៉ាល់ ផាដិន (Royal Pardon)"ៈ ទង្វើឬការធ្វើឲ្យមោឃភាពលើការផ្តន្ទាទោសដែលបានដាក់រួចហើយ ។


អៀង សារី

ចំណែកពាក្យថា ការលើកលែងទោស ឬភាសាអង់គ្លេសហៅថា "អាំណេសធី (Amnesty)"ៈ ជាការលើកលែងដល់ជនណាម្នាក់ដោយរដ្ឋាភិបាលនៅពេលដែលបុគ្គលនោះមិនទាន់បានទទួលការជម្រះក្តីនៅឡើយ ។ ដូច្នេះតាមស្ថានភាពទាំងពីរខាងលើនេះមិនមានស្ថានភាពណាមួយដែលរារាំងការកាត់ទោស អៀង សារី នៅចំពោះយុត្តាធិការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។ ការលើកលែងទោស គឺផ្តល់ឲ្យ អៀង សារី រួចផុតពីទោសប្រហារជីវិត និងដកហូតយកទ្រព្យសម្បត្តិ ។ ម្យ៉ាងទៀតការលើកលែងទោស

នេះ គឺលើកលែងឲ្យរួចផុតពីការចោទប្រកាន់តែលើបទល្មើសដែលមានចែងក្នុងច្បាប់ឆ្នាំ១៩៩៤ ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់តែប៉ុណ្ណោះ ។ ប៉ុន្តែវាមិនមានអានុភាពចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ។ ព្រះរាជក្រឹត្យលើកលែងទោសឲ្យ អៀង សារី មិនបានចែងពីការលើកលែងទោសលើបទឧក្រិដ្ឋអន្តរជាតិមួយចំនួនក្រៅពីបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះទេ មានន័យថាតុលាការប្រជាជន



*អាង ឧត្តម សហមេធាវីជាតិរបស់ អៀង សារី*

បដិវត្តបានចោទប្រកាន់តែទៅលើបទល្មើសមួយប៉ុណ្ណោះ គឺបទល្មើសប្រល័យពូជសាសន៍ ។ ប៉ុន្តែតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានចោទប្រកាន់ទៅលើជនជាប់ចោទ អៀង សារី នូវបទល្មើសអន្តរជាតិជាច្រើនទៀតដោយហេតុថាតុលាការនេះជាតុលាការអន្តរជាតូនីយកម្មដែលត្រូវបានផ្តល់សិទ្ធិឲ្យជំនុំជម្រះលើឧក្រិដ្ឋកម្មជាតិនិងអន្តរជាតិមួយចំនួនដូចជា ៖ បទឧក្រិដ្ឋប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងបទឧក្រិដ្ឋអន្តរជាតិមួយចំនួនទៀត ។ ដូច្នេះការលើកលែងទោសមិនអាចរារាំងការចោទប្រកាន់ អៀង សារី ចំពោះយុត្តាធិការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ ។

ទី២) សហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បានបន្ថែមទៅលើសហភាតាររបស់គាត់ថា ៖ បើទោះជាព្រះរាជក្រឹត្យនេះពិតជាមានវិសាលភាពការពារ អៀង សារី ចំពោះបទល្មើសនៅក្រោមយុត្តាធិការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ ក៏តុលាការនេះមានលក្ខណៈជាតុលាការអន្តរជាតូបនីយកម្ម ដែលប្រើប្រាស់ទាំងច្បាប់ជាតិនិងអន្តរជាតិ ។ ច្បាប់អន្តរជាតិមិនអនុញ្ញាតឲ្យមានការលើកលែងទោស ឬការរារាំងលើការកាត់ក្តីឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមឡើយ ។ កាតព្វកិច្ចរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវឆ្លើយតបទៅនឹងមាត្រា១ នៃអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការការពារ និងផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលតម្រូវឲ្យរដ្ឋធ្វើការការពារនិងកាត់ទោសទៅលើអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ហេតុដូច្នេះ ការលើកលែងទោស គឺផ្ទុយទៅនឹងទំនៀមទម្លាប់អន្តរជាតិនិងអនុសញ្ញាអន្តរជាតិដែលនៅជាធរមានសព្វថ្ងៃ ។

### ក) មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងអញ្ញត្រកម្មនេះភាគីមេធាវីនាំមុខ និងមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រទៅលើការលើកឡើងរបស់សហព្រះរាជអាជ្ញានិងបានលើកឡើងនូវចំណុចមួយចំនួនដូចតទៅ ៖

១) មេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យតែងតែខិតខំច្រានចោលនូវកិច្ចចរចាសន្តិភាព ហើយមេដឹកនាំទាំងនោះមិនដែលចង់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ ។ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរក្រហមថែមទាំងបានព្យាយាមធ្វើការវាយប្រហារធ្វើឲ្យកើនឡើងនូវអំពើហិង្សានយោបាយ ដែលរួមមានទាំងការសម្លាប់កងកម្លាំងរក្សាសន្តិភាពនៅកម្ពុជា ទៀតផង ។

២) ព្រះរាជក្រឹត្យផ្តល់ការលើកលែងទោស គឺធ្វើឡើងក្រោមសម្ពាធនៃការបង្កហិង្សាពីពួកខ្មែរក្រហម ដូចជាការចាប់

ប្រជាជនធ្វើជាចំណាប់ខ្មាំងដោយខ្មែរក្រហមជាដើម ។

៣) ការផ្តល់សុពលភាពដល់ព្រះរាជក្រឹត្យ គឺជាការដកហូតនូវសិទ្ធិទទួលបានសំណង ព្រមទាំងឧបាស្រ័យ៤យ៉ាង ដែលជនរងគ្រោះគួរតែទទួលបាន ដូចជាយុត្តិធម៌ ការអនុវត្តតាមផ្លូវច្បាប់ នីតិវិធីនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងការទទួលបានសំណង ។ ម្យ៉ាងវិញទៀត ការផ្តល់ការលើកលែងទោសដល់ អៀង សារី គឺជាការបង្កើននិទណ្ឌភាពនៅកម្ពុជានិងពិភពលោកលើកាតព្វកិច្ចអន្តរជាតិ ។

## ៤) ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩

អាជ្ញាយុកាលនៃការប្រព្រឹត្តបទល្មើសរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺជាអញ្ញត្រកម្មដ៏សំខាន់ដែលត្រូវតែលើកយកមកពិភាក្សាឲ្យបានច្បាស់លាស់មុនដំណើរការអង្គសេចក្តី ។ បញ្ហាដែលត្រូវលើកឡើងនោះគឺថាតើអាជ្ញាយុកាលនៃបទល្មើស ការរំលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវនេះ អាចអនុវត្តចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? នៅពេលដែលឧក្រិដ្ឋកម្មនេះបានកើតឡើង ប្រទេសកម្ពុជាមិនទាន់ក្លាយជារដ្ឋភាគីនៃអនុសញ្ញានេះនៅឡើយ ។ ម្យ៉ាងទៀត នាពេលនោះ គឺមានរដ្ឋចំនួនតែ១៧ប៉ុណ្ណោះ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ។ មេធាវី អាង ឧត្តម សហមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី បានលើកឡើងនៅក្នុងសវនាការបឋមថា នៅក្នុងមាត្រា៦នៃច្បាប់បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មិនបានចែងពីពាក្យថាគ្មានអាជ្ញាយុកាលនោះទេ ។ ម្យ៉ាងទៀត រាល់ច្បាប់អន្តរជាតិទាំងអស់ត្រូវតែបញ្ចូលឲ្យទៅជាច្បាប់ជាតិជាមុនដើម្បីឲ្យអាចយកមកអនុវត្តបាន ។ ហេតុដូច្នេះ រាល់បទល្មើសដែលបានកើតឡើងនៅសម័យកម្ពុជាប្រជាធិបតេយ្យ ត្រូវតែយកច្បាប់ព្រហ្មទណ្ឌឆ្នាំ១៩៥៦មកអនុវត្ត ។ មេធាវីអន្តរជាតិ កាណាវ៉ាស បានបន្ថែមទៀតថា បញ្ហាអាជ្ញាយុកាលគឺត្រូវមើលទៅលើរបាយការណ៍របស់អង្គការសហប្រជាជាតិ កាលពីឆ្នាំ១៩៦៦ ស្តីអំពីការគាំទ្រ ការកំណត់អាជ្ញាយុកាលដែលបានបញ្ជាក់ពីជំហររបស់ប្រទេសកម្ពុជា ។ របាយការណ៍នោះមានរដ្ឋភាគីច្រើនកំណត់យកអាជ្ញាយុកាលក្រោយ១៩៧៩ ។ ហេតុដូច្នេះ អាជ្ញាយុកាលមិនត្រូវបានយកមកប្រើនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ ។

ជាការឆ្លើយតបទៅនឹងក្រុមមេធាវីការពារក្តីរបស់ អៀង សារី សហព្រះរាជអាជ្ញារងជាតិ វេង ហ៊ិន បានលើកឡើងថា អនុសញ្ញានេះត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិដែលហៅថាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ ដើម្បីឲ្យទទួលបានការទទួលស្គាល់ជាទំនៀមទំលាប់អន្តរជាតិ គឺត្រូវទាមទារឲ្យមានធាតុផ្សំពីរសំខាន់គឺៈ

- ការអនុវត្តរបស់រដ្ឋ *(state practice)*
- គំនិតនៃច្បាប់ *(opinio juris)*



មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ទំនៀមទម្លាប់អន្តរជាតិត្រូវបានបង្កើតឡើងដោយវិធានដែលកើតឡើងពីការអនុវត្តទូទៅ និងដែលត្រូវបានទទួលស្គាល់អនុវត្តដូចជាច្បាប់ដែរ ហើយត្រូវបានបង្កើតឡើងខុសពីច្បាប់ ។ អនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រឹមតែជាបទដ្ឋានទំនៀមទម្លាប់អន្តរជាតិតែប៉ុណ្ណោះទេ អនុសញ្ញានេះត្រូវបានទទួលស្គាល់ថាជាបទដ្ឋានអាជ្ញាបញ្ញា *(jus cogen)* ដែលមានលក្ខណៈចាប់បង្ខំ និងជាកាតព្វកិច្ចដល់រដ្ឋនៅក្នុងការអនុវត្តជាទូទៅនៅក្នុងច្បាប់អន្តរជាតិ ។ បទដ្ឋានអាជ្ញាបញ្ញា ជាបទដ្ឋានខ្ពស់ជាងគេបំផុតនៅក្នុងឋានានុក្រមច្បាប់អន្តរជាតិ ហើយដែលរដ្ឋទាំងអស់ត្រូវតែអនុវត្តតាម ។ សហព្រះរាជអាជ្ញាបានបន្តទៀតថា អំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មអន្តរជាតិមួយដែលចាប់បង្ខំឲ្យរដ្ឋទាំងអស់អនុវត្តនូវកាតព្វកិច្ចក្នុង

ការចោទប្រកាន់ ស៊ើបអង្កេត និងផ្តន្ទាទោស ។ ជំនួយការជាន់ខ្ពស់សហព្រះរាជអាជ្ញាអន្តរជាតិ ថារិក អាប់ឌុល បានលើកឡើងថា នៅក្នុងមាត្រា៦នៃច្បាប់ស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម បានរាប់បញ្ចូលការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ជាឧក្រិដ្ឋកម្មអន្តរជាតិ ។ ទោះបីជាមុនឆ្នាំ១៩៧៥ អនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័នតែ១៧ប្រទេសក៏ដោយ អនុសញ្ញានេះចូលជាធរមានតាំងពីឆ្នាំ១៩៧០ ហើយអនុសញ្ញានេះជាគោលការណ៍សាកល ហេតុដូច្នេះវាមានអានុភាពចាប់បង្ខំឲ្យអនុវត្តជាអន្តរជាតិ ។ មាត្រា៦នៃអនុសញ្ញានេះបានមិនបានកំណត់ពីអាជ្ញាយុកាលនោះទេ ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំទៅអង្គជំនុំជម្រះឲ្យចាត់ទុកអនុសញ្ញាទីក្រុងហ្សឺណែវនេះថាអនុសញ្ញានេះគ្មានអាជ្ញាយុកាលចំពោះបទល្មើសបទល្មើសដែលត្រូវបានប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ។ និយាយម្យ៉ាងទៀត សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះយល់ឃើញថា ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវនេះអាចយកមកជំនុំជម្រះទោសអតីតមេដឹកនាំខ្មែរក្រហមបាន ។

## ៥) អាជ្ញាយុកាលរបស់បទល្មើសជាតិដែលមាននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

នៅថ្ងៃទីបីនៃដំណើរការសវនាការបឋមលើសំណុំរឿង ០០២នេះ បញ្ហាដែលត្រូវបានលើកយកមកពិភាក្សាគឺអញ្ញត្រកម្មអំពីអាជ្ញាយុកាលនៃបទល្មើសជាតិនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានលើកឡើងដោយសហមេធាវីរបស់ជនជាប់ចោទ ។ បទល្មើសជាតិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មានបីគឺៈ

- មនុស្សឃាត
- ការធ្វើទារុណកម្ម និង
- ការធ្វើទុកបុកម្នេញខាងសាសនា

អាជ្ញាយុកាលនៃបទល្មើសជាតិទាំងបីខាងលើនេះមានរយៈពេល១០ឆ្នាំ ។

ពាក់ព័ន្ធទៅនឹងការពន្យារអាជ្ញាយុកាលនេះភាគីមេធាវីរបស់ អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ បានលើកឡើងនូវទឡ្ហីករណ៍មួយចំនួនដូចជាៈ

- អាជ្ញាយុកាលនៃបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦មិនអាចព្យួរបាន ដោយសារតែអាជ្ញាយុកាលនៃបទល្មើសនេះត្រូវបានកាត់ផ្តាច់ដោយមានការជំនុំជម្រះក្តីកាលពីឆ្នាំ ១៩៧៩ ។
- អាជ្ញាយុកាលជាពេលវេលាមួយដែលទុកសម្រាប់ឲ្យជននោះត្រឡប់មកផ្សះផ្សានៅក្នុងសង្គមវិញ ។
- ការពន្យារពេលអាជ្ញាយុកាលជាការខុសឆ្គងមួយដែលធ្វើឲ្យមានការរំលោភលើគោលការណ៍ទទួលបានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ។

សហមេធាវីការពារជនជាប់ចោទ អៀង សារី បានអះអាងថាការពន្យារអាជ្ញាយុកាលរហូតដល់រយៈពេល៣០ឆ្នាំនេះ គឺប៉ះពាល់ទៅលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ ។ មេធាវីបានបន្តទៀតថា មាត្រា៣នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលបានពន្យារពេលអាជ្ញាយុកាលបទល្មើសក្នុងស្រុកចំនួន៣០ឆ្នាំ មិនអាចយកមកអនុវត្តបានទេ ដោយសារតែវាប៉ះពាល់ដល់យុត្តាធិការពេលវេលា ជាពិសេសគឺរំលោភទៅលើគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌជាគោលការណ៍មួយនៅក្នុងយុត្តាធិការពេលវេលា ដែលគោលការណ៍នេះធានាមិនឲ្យមានការអនុវត្តថយក្រោយនៃច្បាប់ព្រហ្មទណ្ឌមានន័យថា អំពើល្មើសណាមួយអាចត្រូវបានផ្តន្ទាទោសតែក្នុងរយៈពេលមួយជាក់លាក់ប៉ុណ្ណោះ ។ នៅក្នុងករណីបទល្មើសព្រហ្មទណ្ឌជាតិនេះ គេអាចប្រើច្បាប់នេះមកកាត់ទោសជនល្មើសណាមួយតែក្នុងរយៈពេល១០ឆ្នាំក្រោយការប្រព្រឹត្តបទល្មើសនោះប៉ុណ្ណោះ ។ នេះមានន័យថា គេអាចផ្តន្ទាអតីតមេដឹកនាំខ្មែរក្រហមដោយប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ បានត្រឹមតែ ឆ្នាំ១៩៨៩ ប៉ុណ្ណោះ ដោយសារថាអាជ្ញាយុកាលនៃបទល្មើសនេះមានត្រឹមតែរយៈពេល១០ឆ្នាំ ។ ក្រោយរយៈពេលនេះ មេដឹកនាំខ្មែរក្រហមមិនអាចត្រូវបានផ្តន្ទាទោសចំពោះបទល្មើសជាតិដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ទេ ។ សហមេធាវីអន្តរជាតិ កាណាវ៉ាស បានបន្ថែមទៀតថា មាត្រា៣ថ្មីនៃច្បាប់បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះមិនអាចអនុវត្តបានទេដោយសារ


អៀង ធិរិទ្ធ ហៅ
សមមិត្ត ភា


អៀង សារី ហៅ
សមមិត្ត វ៉ាន់

តែមាត្រានេះរំលោភបំពានទៅគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ។ ទោះបីជាមាត្រា៣នេះ ត្រូវបានសន្មតថា ស្របតាមរដ្ឋធម្មនុញ្ញក៏ដោយ ក៏គោលការណ៍ប្រតិសកម្មគឺជាគោលការណ៍គ្រឹះសំខាន់ដែលមិនអាចយកមកអនុវត្តលើជនជាប់ចោទ អៀង សារី ទេ ។

មេធាវីបានបន្ថែមទៀតថា មាត្រា១០៩នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អនុញ្ញាតឲ្យមានការព្យួរ ឬបន្តនូវអាជ្ញាយុកាលនៃបទល្មើសបាន ។ ប៉ុន្តែមេធាវី កាណាវ៉ាស បានបញ្ជាក់បន្ថែមថា លក្ខខណ្ឌនៅក្នុងការព្យួរអាជ្ញាយុកាលនេះអាចធ្វើទៅបានក្នុងករណីដែលមានមិនមានហេតុការណ៍ណាមួយចូលមកកាត់អាជ្ញាយុកាលនោះ ដូចជាមានការស៊ើបអង្កេតលើបទល្មើសនោះជាដើម ។ នៅក្នុងករណីរបស់ អៀង សារី អាជ្ញាយុកាលត្រូវបានកាត់ផ្ដាច់នៅពេលដែលមានការជំនុំជម្រះនៅក្នុងឆ្នាំ១៩៧៩ ។ ហើយបន្ទាប់ពីនោះគឺពីឆ្នាំ១៩៧៩ដល់១៩៩១ មិនមានការស៊ើបអង្កេត ឬវិនិច្ឆ័យអ្វីបន្ថែមទៀតនោះទេ ហេតុដូចនេះអាជ្ញាយុកាល គឺមិនអាចបន្តទៅមុខទៀតបានឡើយ ។ មិនតែប៉ុណ្ណោះ យោងតាមអនុសញ្ញាឆ្នាំ១៩៦៨ ហាមឃាត់មិនឲ្យមានការអនុវត្តនូវគោលការណ៍ប្រតិសកម្មនោះទេ ពោលគឺបើផុតអាជ្ញាយុកាលហើយមិនអាចយកច្បាប់នោះមកកាត់ទោសបានឡើយ ។

ចំពោះឯខាងសហមេធាវីជាតិ ស សូវ៉ាន ការពារជនជាប់ចោទ ខៀវ សំផន បានលើកឡើងថា អាជ្ញាយុកាលជាពេលវេលាមួយដែលទុកឲ្យបំភ្លេចដើម្បីឲ្យជននោះចូលមករួមរស់នៅក្នុងសង្គមវិញ ។

ដុយពីមេធាវីរបស់ ខៀវ សំផន មេធាវីជាតិរបស់ជនជាប់ចោទ អៀង ធីរិទ្ធ មេធាវី ផាត់ ពៅស៊ាង បានបញ្ជាក់ថា ទាំងសងខាងត្រូវការពាក្យថាយុត្តិធម៌ ដូច្នេះត្រូវយកច្បាប់ជាគោល ។ ហើយចំពោះអាជ្ញាយុកាលដែលបានផុតរលត់ទៅហើយ ទើបប្រើច្បាប់ដើម្បីពន្យារអជ្ញាយុកាល នោះជាការខុសឆ្គងមួយ ។

ក្នុងការឆ្លើយតបទៅនឹងបញ្ហាអាជ្ញាយុកាលនោះសហព្រះរាជអាជ្ញារងជាតិបានស្នើសុំឲ្យអង្គជំនុំជម្រះលាសាដំបូងបដិសេធការស្នើសុំរបស់ភាគីជនជាប់ចោទពាក់ព័ន្ធទៅនឹងអាជ្ញាយុកាលនៃបទល្មើស ជាតិនេះ ។

សហព្រះរាជអាជ្ញាបានបន្តថា អាជ្ញាយុកាលមិនទាន់ត្រូវបានផុតរលត់នៅឡើយទេ ដោយសារមានលក្ខខណ្ឌមួយចំនួនបានពន្យារពេលអាជ្ញាយុកាលនេះ ។ លក្ខខណ្ឌទាំងនោះរួមមាន :

១) មិនមានការចែងពីអាជ្ញាយុកាល

២) គោលការណ៍ទូទៅនៃការព្យួរអាជ្ញាយុកាល

៣) ដោយសារមិនមានប្រពន្ធ័ច្បាប់

៤) ប្រទេសកំពុងមានសង្គ្រាម

៥) កំហុសរបស់ជនល្មើស ។

នៅក្នុងសវនាការ ព្រះរាជអាជ្ញាបានលើកឡើងថា ប្រព័ន្ធច្បាប់កម្ពុជានៅសម័យកម្ពុជាប្រជាធិបតេយ្យត្រូវបានវិនាសខ្ទាត់ខ្ទាយ ហើយរយៈពេលពីឆ្នាំ១៩៧៩ដល់១៩៩១ ប្រព័ន្ធតុលាការរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា គឺអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលដែលមានប្រភពចេញមកពីបារាំង ហើយក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនត្រូវបានយកមកអនុវត្តនោះទេ ដោយអនុវត្តតែក្រឹត្យច្បាប់ឆ្នាំ១៩៨០ ។ ហើយពេលនោះអ្នកដែលមានចំណេះដឹងផ្នែកច្បាប់មានភាពខ្វះខាតខ្សោយនៅឡើយ តុលាការខ្វះខាតអ្នកចេះដឹង ហេតុដូច្នេះហើយធ្វើឲ្យប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានមេធាវី និងប្ដឹងឧទ្ធរណ៍ ។ ហេតុដូច្នេះ យើងឃើញថាប្រព័ន្ធតុលាការនៅពេលនោះនៅមានកម្រិតនៅឡើយ ។ ក្រោយឆ្នាំ១៩៩២ បន្ទាប់ពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសមក គឺមានការបង្កើតច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌដែលហៅថាច្បាប់អន្តរកាល ហេតុនេះឃើញថាតុលាការនៅតែមានភាពខ្វះខាត ។ រហូតមកដល់ឆ្នាំ១៩៩៣ ទើបមានរដ្ឋធម្មនុញ្ញ និងមានការបង្កើតច្បាប់នានាដែលអាចឲ្យជនជាប់ចោទទទួលបាននូវសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។

លោកសហព្រះរាជអាជ្ញារងជាតិរូបនេះក៏បានលើកឡើងដែរថា ដោយសារតែសន្តិសុខសង្គមនៅមានភាពចលាចល ព្រោះជនជាប់ចោទនៅតែបន្តអសន្តិសុខ ហើយជនជាប់ចោទនៅតែប្រឆាំងនឹងរដ្ឋាភិបាលជាបន្តបន្ទាប់ ទើបបណ្ដាលឲ្យប្រទេសមានសង្គ្រាម ដែលនាំឲ្យមានការរារាំងមិនឲ្យមានការចោទប្រកាន់និងស៊ើបអង្កេតកើតឡើង ។ ហេតុនេះហើយជនជាប់ចោទមិនអាចទទួលបានអត្ថប្រយោជន៍ខាងអាជ្ញាយុកាលនេះទេ ដោយសារតែជនជាប់ចោទជាអ្នកបំផ្លាញនីតិវិធីតុលាការ ។ លើសពីនេះទៅទៀតមាត្រា៣នៃច្បាប់ស្ដីពីការបង្កើតតុលាការកាត់ទោសមេដឹក

នាំខ្មែរក្រហមបានត្រូវប្រកាសថា មានធម្មនុញ្ញភាពដោយឧត្តមក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ហើយដែលសេចក្តីសម្រេចនេះបិទផ្លូវតវ៉ា ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាស្ថាប័នមួយដោយឡែក ហើយមិនមានសិទ្ធិត្រួតពិនិត្យលើសេចក្តីសម្រេចនោះទេ ដូច្នេះ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវតែគោរពច្បាប់ ពោលគឺគោរពតាមសេចក្តីសម្រេចនេះ ។ អ្វីដែលសំខាន់នោះ លោកសហព្រះរាជអាជ្ញារងអន្តរជាតិ វីលៀម ស្មីត បានលើកអំណះអំណាងថា មាត្រា៣នៃច្បាប់ស្តីពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនបានរំលោភទៅលើគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌនិងសិទ្ធិស្មើគ្នាចំពោះមុខច្បាប់របស់ជនជាប់ចោទនោះទេ ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ការពន្យាអាជ្ញាយុកាលតាមមាត្រា៣នេះ គឺធ្វើឡើងនៅពេលដែលអាជ្ញាយុកាលមិនទាន់ផុតរលត់នៅឡើយទេ ។ ជាការពិត ការពន្យាអាជ្ញាយុកាលអាចធ្វើទៅបានអាស្រ័យទៅលើកាលៈទេសៈច្បាស់លាស់ ។ ការលើកឡើងរបស់មេធាវីគឺមិនសមស្របនោះទេ ដោយសារក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ មិនត្រូវបាននិរាករណ៍ ដោយក្រឹត្យច្បាប់១៩៨០ ហើយក្រឹត្យច្បាប់នេះគឺផ្តោតតែទៅលើទោសក្បត់បដិវត្តន៍តែប៉ុណ្ណោះ ។ លោក ស្មីត បានលើកឡើងថាមាត្រា៣០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលបានបន្តអាជ្ញាយុកាលនៃបទឧក្រិដ្ឋរយៈពេល១០ឆ្នាំ ដូច្នេះ កាលបរិច្ឆេទដំបូងនៃការចាប់ផ្តើមរាប់អាជ្ញាយុកាលគឺខែវិច្ឆិកា ឆ្នាំ១៩៩២ ហេតុនេះហើយអាជ្ញាយុកាលមិនទាន់ផុតរលត់នៅឡើយ ហើយវាបានបន្តមកដល់២០០១ ទើបអាចពន្យាបាន ៣០ឆ្នាំទៀត ដោយច្បាប់បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ការគិតពីអាជ្ញាយុកាលនេះ គឺគិតរួមផ្សំទាំងគោលការណ៍ច្បាប់ និងការវិនិច្ឆ័យទៅលើបរិបទផ្សេងទៀតដូចជា ៖

- គោលការណ៍ព្យួរទោស
- ដោយសារមិនមានប្រព័ន្ធច្បាប់
- សង្គ្រាមដែលបង្កឡើងដោយជនជាប់ចោទ ។

ការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិក៏មិនមានអ្វីបន្ថែមក្រៅពីសហភាគីរបស់គាត់ គ្រាន់តែលោកចង់បញ្ជាក់ឲ្យកាន់តែច្បាស់នូវចំណុចមួយចំនួនខាងលើនេះថា ដោយសារមុនកំណែទម្រង់ប្រព័ន្ធតុលាការពី១៩៩២-១៩៩៣នោះ តុលាការមិនបានផ្តល់យុត្តិធម៌ដល់ជនជាប់ចោទ និងជនរងគ្រោះនោះទេ ។ ម្យ៉ាងទៀតដោយសារមានសង្គ្រាមទើបបណ្តាលឲ្យមានការពន្យាអាជ្ញាយុកាល ហើយការបង្កសង្គ្រាមនេះជាកំហុសផ្ទាល់របស់ជនជាប់ចោទ ហេតុនេះជនជាប់ចោទមិនអាចទទួលបានអត្ថប្រយោជន៍ពាក់ព័ន្ធទៅនឹងអាជ្ញាយុកាលនេះទេ ។

ចំពោះអញ្ញត្រកម្មពាក់ព័ន្ធទៅនឹងអាជ្ញាយុកាល ខាងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រទាំងស្រុងចំពោះការលើកឡើងរបស់សហព្រះរាជអាជ្ញា ហើយដោយគ្រាន់តែលើកនូវអំណះអំណាងខ្លះៗក្នុងការគាំទ្រនេះ ។ លោកស្រីមេធាវីបានលើកឡើងអំពីសមភាពចំពោះមុខច្បាប់ដែលជនរងគ្រោះត្រូវតែបានទទួល ហើយដើម្បីទទួលបាននូវយុត្តិធម៌ នេះជាការទាមទារឲ្យមានអ្នកទទួលខុសត្រូវ ។ មានតែតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេដែលអាចឆ្លើយតបនឹងការឈឺចាប់នេះ ។ លើសពីនេះលោកស្រីក៏បានលើកឡើងពីគោលការណ៍សមភាពរវាងយុត្តិធម៌និងការទទួលខុសត្រូវដែលជនល្មើសត្រូវតែទទួលខុសត្រូវ ។ ម្យ៉ាងទៀត តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអាចពន្យាអាជ្ញាយុកាលបាន ព្រោះមាត្រា៣បានត្រូវបានបកស្រាយដោយឧត្តមក្រុម



**ប៊ូ ម៉េង (អតីតអ្នកទោសមន្ទីរស-២១) កំពុងផ្តល់បទសម្ភាសន៍ដល់អ្នកសារព័ត៌មាន**

ប្រឹក្សារដ្ឋធម្មនុញ្ញថា មិនមានអធម្មនុញ្ញភាពនោះទេ ។ សរុបមក លោកស្រីបានបញ្ជាក់យ៉ាងមុតមាំថា ការអនុញ្ញាតឲ្យមានការផុតអាជ្ញាយុកាលមិនអាចនាំមកនូវយុត្តិធម៌បានឡើយ ។

## ៦) សក្ខីកម្មផ្ទាល់មាត់ទាក់ទងទៅនឹងបញ្ជីឈ្មោះសាក្សី

បើពិនិត្យមើលការផ្តល់សក្ខីកម្មផ្ទាល់មាត់ទាក់ទងទៅនឹងការស្នើសុំដាក់បញ្ជីឈ្មោះសាក្សីដោយភាគីទាំងអស់នៅថ្ងៃចុងក្រោយនៃសវនាការបឋម តុលាការបានចាប់ផ្តើមជាសាធារណៈដោយបានអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើការដេញដោលគ្នាចំពោះមុខសារណៈជន ។ ប៉ុន្តែនៅពេលដែលគូភាគីទាំងអស់ឈានដល់ដំណាក់កាលបង្ហើបពីអត្តសញ្ញាណរបស់សាក្សី ប្រធានតុលាការបានប្រកាសថា សវនាការបន្ទាប់នឹងត្រូវឡើងធ្វើជាអសាធារណៈដើម្បីធានាដល់ថែរក្សាអត្តសញ្ញាណរបស់សាក្សីអ្នកជំនាញនិងដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយស្របទៅនឹងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជា ។

នៅក្នុងដំណាក់កាលដេញដោលជាសាធារណៈនេះ នៅពេលចាប់ផ្តើមដំបូងខាងភាគីសហព្រះរាជអាជ្ញាចាប់ស្នើសុំឲ្យដកសាក្សីម្នាក់ដែលមានអត្តលេខសំគាល់ខ្លួន *TWC-482* ហើយនឹងបានស្នើសុំទៅក្រុមប្រឹក្សាជំនុំជម្រះឲ្យបើកធ្វើសវនាការជាអសាធារណៈនៅក្នុងរយៈពេលខ្លីមួយដើម្បីជជែកពិភាក្សាដេញដោលអំពីមូលហេតុនៃការដកឈ្មោះសាក្សីនេះចេញពីបញ្ជីឈ្មោះសាក្សី ។ សហព្រះរាជអាជ្ញាបានបញ្ជាក់ប្រាប់អង្គសវនាការថា ខ្លួនមានបំណងចង់ដាក់បន្ថែមសាក្សីចំនួន១៥នាក់ ថែមទៀតនៅពេលក្រោយ ។

ក្រោយពីសហព្រះរាជអាជ្ញាបានឡើងធ្វើការស្នើសុំរបស់ខ្លួនហើយ ប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាទៅឲ្យខាងមេធាវីការពារក្តីទាំងបួនក្រុមរបស់ជនជាប់ចោទដើម្បីធ្វើការស្នើសុំរបស់ខ្លួនទាក់ទងទៅនឹងបញ្ហាបញ្ជីឈ្មោះរបស់សាក្សី ។ ខាងភាគីមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា បានលើកឡើងមុនគេអំពីបញ្ហាបញ្ជីឈ្មោះសាក្សីរបស់ខ្លួនដែលបានដាក់ជូនទៅឲ្យសហចៅក្រមស៊ើបអង្កេតដើម្បីធ្វើការសាកសួរ ប៉ុន្តែភាគច្រើននៃសាក្សីទាំងនោះត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធ ហើយសាក្សីដទៃផ្សេងទៀតមិនត្រូវបានកោះហៅយកមកសាកសួរឡើយ ។ លើសពីនេះទៅទៀត មេធាវីការពារជនជាប់ចោទ នួន ជា បានលើកឡើងថា នួន ជា ចង់ឲ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតទៅលើតួនាទីរបស់ប្រទេសវៀតណាមនៅមុនពេល អំឡុងពេល និងក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យ និងស៊ើបអង្កេតពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកមកលើប្រទេសកម្ពុជាថែមទៀត ។ បើយោងទៅលើការលើកឡើងរបស់មេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា បានបង្ហាញឲ្យដឹងថា នួន ជា ចង់ឲ្យសវនាការជំនុំជម្រះក្តីនេះធ្វើឡើងដោយឆាប់រហ័ស ព្រោះអាយុរបស់គាត់កាន់តែចាស់ទៅហើយ មិនដឹងថាគាត់អាចបន្តរស់នៅបានប៉ុន្មានឆ្នាំទៀតឡើយ ។ ដោយគាត់ចង់បង្ហាញឲ្យប្រជាជនទូទៅបានដឹងពីការពិតនៅក្នុងសម័យនោះ ហើយទទូចថាសុំឲ្យសវនាការដែលកាត់ក្តីរូបគាត់នេះ ត្រូវតែជាសវនាការមួយប្រកបទៅដោយការពិត ។ មិនមែនគ្រាន់តែមើលទៅលើសៀវភៅប្រវត្តិសាស្ត្រដែលនិពន្ធជាភាសាអង់គ្លេស ឬជាភាសាវៀតណាមនោះទេ ។ ដើម្បីដឹងការពិតគេត្រូវតែយកសាក្សីដែលនៅកាន់កាប់ខាងភូមិភាគបូព៌ាកាលពីសម័យខ្មែរក្រហមនោះមកធ្វើការសាកសួរ ព្រោះមានតែអ្នកទាំងនោះទេដែលដឹងច្បាស់ពីរឿងពិតនៅក្នុងសម័យនោះ ហើយថែមទាំងដឹងច្បាស់ទៅទៀតពីតួនាទីរបស់អាមេរិកនិងប្រទេសវៀតណាមនៅក្នុងសម័យនោះ ។

ក្រោយមកលោក មេធាវីការពារក្តីរបស់លោក នួន ជា ត្រូវបានលោកប្រធានចៅក្រម និល ណុន បញ្ឈប់មិនឲ្យបន្តការលើកឡើងរបស់គាត់ ដោយសារហេតុផលថាមេធាវីការពារក្តីរបស់ នួន ជា បើទោះបីជាមិនបានបញ្ចេញឈ្មោះរបស់សាក្សីនោះមែន ប៉ុន្តែបានផ្តល់ព័ត៌មានភាគច្រើនអំពីសាក្សីមួយរូបនេះ ដូចជាធ្លាប់មានតួនាទីជាអតីតនាយករដ្ឋមន្ត្រីទីមួយ នៅក្នុងសម័យរដ្ឋកម្ពុជាជាដើម ។ សាធារណៈជនពិតជាអាចកាត់យល់បានថា អ្នកដែលមេធាវី នួន ជា ចង់និយាយនោះគឺជាលោក ប៉ែន សុវណ្ណ ។ បន្ទាប់ពីការរៀបរាប់អត្តសញ្ញាណរបស់សាក្សីនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបញ្ឈប់មិនឲ្យមេធាវី នួន ជា បន្តការលើកឡើងរបស់ខ្លួនទៀតទេ ដោយអង្គជំនុំជម្រះយល់ឃើញថា អត្តសញ្ញាណរបស់សាក្សីត្រូវតែរក្សាជាសមាត់នៅក្នុងដំណាក់កាលនេះ ដោយសារមូលហេតុជាច្រើន ហើយមូលហេតុដែលសំខាន់ជាងគេគឺសន្តិសុខរបស់សាក្សី ។

ចំណែកឯខាងសហមេធាវី កាណាវ៉ាស ការពារក្តីឲ្យជនជាប់ចោទ អៀង សារី មិនបានលើកឡើងអ្វីច្រើនទាក់ទងនឹងបញ្ហាបញ្ជីឈ្មោះសាក្សីនេះទេ គ្រាន់តែធ្វើការស្នើទៅអង្គជំនុំជម្រះសាលាដំបូងឲ្យបដិសេធចោលនូវសាក្សីដែលមានលេខសំគាល់ TCE-44 ដោយស្នើសុំឲ្យធ្វើការដេញដោលពីបញ្ហាបញ្ជីឈ្មោះរបស់សាក្សីនេះធ្វើឡើងនៅក្នុងសវនាការអសាធារណៈ ។

ចំពោះខាងសហមេធាវីការពារក្តីឲ្យលោកស្រី អៀង ធីរិទ្ធ វិញ បានក្រោកឈរឡើង ហើយជម្រាបជូនទៅអង្គជំនុំជម្រះថា គាត់មិនមានការជំទាស់អ្វីទាក់ទងនឹងបញ្ជីឈ្មោះរបស់សាក្សីនោះទេ ។

ខុសពីសហមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីរូបមុន មេធាវី ស សូវ៉ាន ដែលជាសហមេធាវីជាតិការពារក្តីឲ្យលោក ខៀវ សំផន មិនបានឡើងថ្លែងពីបញ្ហាបញ្ជីឈ្មោះសាក្សីដោយខ្លួនឯងឡើយ ប៉ុន្តែគាត់បានប្រគល់វេទិការនោះទៅឲ្យលោក ខៀវ សំផន ដែលជាអតីតប្រមុខរដ្ឋនៅក្នុងសម័យខ្មែរក្រហមឡើងបង្ហាញពីមតិផ្ទាល់ខ្លួនរបស់គាត់ចំពោះបញ្ហាបញ្ជីឈ្មោះសាក្សីដែលគាត់បានស្នើ សុំទៅសហចៅក្រមស៊ើបអង្កេតកាលពីពេលមុន ។ ខៀវ សំផន បានរៀបរាប់ថា ៖

“សូមអរគុណលោកប្រធាន ដែលបានអនុញ្ញាតឲ្យខ្ញុំឡើងមានមតិនៅពេលនេះ ។ សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីទាំងអស់ដែលមានមុខនៅទីនេះ ។ សូមគោរពបងប្អូនជនរួមជាតិទាំងអស់ សូមថ្វាយបង្គំគោរពព្រះសង្ឃគ្រប់ព្រះអង្គ ។ ពេលនេះខ្ញុំយល់ឃើញថា ជាពេលដែលមានសារៈសំខាន់បំផុតចំពោះខ្ញុំក៏ដូចជាបងប្អូនជនរួមជាតិទាំងអស់ដែលស្រេកឃ្លានចង់ដឹង ចង់យល់ អំពីអ្វីដែលបានកើតឡើងនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំបានរង់ចាំពេលនេះជាយូរណាស់មកហើយ ។ ជាភ័ព្វសំណាងខ្ញុំមានសុខភាពល្អនៅពេលនេះ ។ ហើយបើកាលណាលំដាប់ណាខ្ញុំនៅមានសុខភាពល្អដូចសព្វថ្ងៃនេះ ខ្ញុំនឹងរួមចំណែកឲ្យអស់ពីកម្លាំងចិត្ត កម្លាំងកាយរបស់ខ្ញុំដល់ការងាររបស់តុលាការ ដើម្បីធ្វើម៉េចអ្វីដែលបានដែលឡើងនៅអំឡុងឆ្នាំដែលខ្ញុំបាននិយាយអម្បាញ់មិញនេះវាលេចចេញឡើងឲ្យបានច្បាស់ ។ ផ្ទាល់ខ្លួនខ្ញុំ ខ្ញុំមិនដឹងអស់ទេ ក៏ប៉ុន្តែខ្ញុំរួមចំណែកអស់ពីចិត្តពីថ្លើមដើម្បីធ្វើម៉េចឲ្យវាលេចចេញឡើងឲ្យអស់ ។ ឯចំពោះបញ្ជីសាក្សីវិញ ខ្ញុំក៏បានស្តាប់ប្រសាសន៍លោកប្រធានបានជម្រាបអង្គប្រជុំរួចហើយថា បញ្ជីនេះគ្រាន់តែជាបញ្ជីបណ្តោះអាសន្នសម្រាប់៤ ជំហានដំបូងនៃដំណើរកាត់ក្តីនេះទេ ហើយខ្ញុំចងចាំប្រសាសន៍របស់លោកប្រធាននេះជាប់ថា មិនមានសាក្សីណាមួយត្រូវបានបដិសេធទេ ។ ដូច្នេះខ្ញុំមិនចាំបាច់និយាយវែងឆ្ងាយអំពីបញ្ជីសាក្សីនេះទេ ខ្ញុំគ្រាន់តែមានមតិជាទូទៅខ្លះតែប៉ុណ្ណោះ ។ ខ្ញុំកត់សំគាល់ឃើញថា សាក្សីភាគច្រើននៅក្នុងបញ្ជីនេះ គឺជាសាក្សីរបស់សហព្រះរាជអាជ្ញាភាគច្រើន ភាគច្រើនលើសលុបសឹងតែទាំងស្រុង ។ ប៉ុន្តែសាក្សីខាងខ្ញុំបែរជាមិនឃើញទៅវិញ មានឃើញដែរ ប៉ុន្តែឃើញតែសាក្សីរបស់ខ្ញុំ ប៉ុន្តែសហព្រះរាជអាជ្ញាចាត់ទុកថាជាសាក្សីរបស់លោកដែរ ។ លោកយល់ថា សាក្សីនេះជាសាក្សីដាក់បន្ទុកលើខ្ញុំ ឯខ្ញុំឃើញថាសាក្សីនោះជាសាក្សីដោះបន្ទុកឲ្យខ្ញុំ ក៏ប៉ុន្តែសាក្សីដែលខ្ញុំសុំនោះអត់មានឃើញឈ្មោះនៅក្នុងបញ្ជីនេះទេ ។ ដូច្នេះខ្ញុំយល់ឃើញថា ការរួមចំណែករបស់ខ្ញុំដើម្បីឲ្យដំណើរកាត់ក្តីនេះវាដំណើរការទៅបានល្អ ត្រឹមត្រូវ ដើម្បីឲ្យការពិត និងភាពត្រឹមត្រូវ ភាពស្មោះត្រង់របស់ខ្ញុំវាលេចឡើងបាន ។ លុះត្រាតែតុលាការយល់ស្របសុខចិត្តស្តាប់សាក្សីសំខាន់ៗរបស់ខ្ញុំ សាក្សីខ្លះរបស់ខ្ញុំ ស្គាល់ខ្ញុំច្បាស់ ព្រោះរស់នៅជាប់ជាមួយខ្ញុំ ដឹងថាខ្ញុំធ្វើអ្វីខ្លះ ទៅណាខ្លះ មកណាខ្លះ អាហ្នឹងក៏ត្រូវការស្តាប់ ។ សាក្សីខ្លះនិយាយតែការងាររបស់គាត់ទេ ក៏ប៉ុន្តែគាត់និយាយពីការងាររបស់គាត់នោះ វាឆ្លុះបញ្ចាំងមកការងាររបស់ខ្ញុំវាស្អី ។ ដូច្នេះវាសំខាន់ត្រង់ហ្នឹងត្រង់ហ្នឹងហើយដែលខ្ញុំយល់ឃើញថាគួរតែត្រូវស្តាប់សាក្សីទាំងអស់នេះ មិនមែនគួរទេគឺចាំបាច់ស្តាប់ ពីព្រោះអី ពីព្រោះការនិយាយពីខ្ញុំនោះ វានិយាយច្រើនហួសហេតុពេក ហើយនិយាយខុសស្រឡះតែម្តង ។ ដូច្នេះខ្ញុំសូមលោកប្រធាន សូមលោកចៅក្រម សូមអស់លោកទាំងអស់ស្តាប់ចាំនូវសំណូមពររបស់ខ្ញុំដូចបានជម្រាបនេះ ហើយខ្ញុំនឹងជូនបញ្ជីសាក្សីរបស់ខ្ញុំ ដោយលាយលក្ខណ៍អក្សរនៅពេលក្រោយ ដើម្បីបញ្ជាក់ថែមឲ្យច្បាស់ថែមទៀត ។ ខ្ញុំសូមមានមតិយោបល់តែប៉ុណ្ណោះទេ សូមជម្រាបអរគុណលោកប្រធាន សូមជម្រាបអរគុណលោកចៅក្រមទាំងអស់ ហើយក៏សូមអរគុណអស់លោក លោកអ្នកទាំងអស់ បងប្អូនរួមជាតិទាំងអស់ ព្រះសង្ឃទាំងអស់ដែលនៅទីនេះ ។ សូមអរគុណ ។

បន្ទាប់ពីសហមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបួនរូបឡើងធ្វើសំណើសុំទាក់ទងនឹងបញ្ជីឈ្មោះរបស់សាក្សីរួចហើយ ប្រធានអង្គជំនុំជម្រះសាលាដំបូងចៅក្រម និល ណុន បានប្រគល់វេទិការទៅឲ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៉ែត ស៊ីមូណូ ហ្វុត ឡើងធ្វើសំណើរសុំរបស់ខ្លួនចំពោះបញ្ហាបញ្ជីឈ្មោះសាក្សី ដែលខ្លួនចង់លើកឡើងនៅក្នុងសវនាការ ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សាក្សីដែលមានអត្តលេខសំគាល់ *TCW-608* ត្រូវតែកោះហៅមកផ្តល់សក្ខីកម្ម ហើយប្រសិនបើសាក្សីនេះត្រូវបានដកចេញពីបញ្ជីឈ្មោះសាក្សីដោយសារសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ សាក្សីនេះនឹងត្រូវដាក់ឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់ខាងតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវី ម៉ាទីន ហ្សាកាំង បានបន្តថា សាក្សីមានលេខសំគាល់ *TCW-348* មានឈ្មោះនៅក្នុងបញ្ជីរបស់សាក្សីខាងដើមបណ្តឹងរដ្ឋប្បវេណី ។ ចំណែកសាក្សីដែលមានលេខសំគាល់ *TCW-531* មិនទាន់ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយគាត់មិនព្រមទេធ្វើសាក្សីទេ ប្រសិនបើគាត់មិនត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី ស្ទូតហ្សីងស្គី បានក្រោកឡើងធ្វើការស្នើសុំឲ្យទទួលស្គាល់សាក្សីដែលមានអត្តលេខសំគាល់ *TCW 604, TCW-707* និង *TCW-126* ។

ក្រោយពីមានសវនាការផ្ទាល់មាត់ជាសាធារណៈទៅលើការស្នើសុំរបស់គូភាគីទៅលើបញ្ជីឈ្មោះរបស់សាក្សីទាំងអស់នោះ អង្គជំនុំជម្រះបានបន្តនីតិវិធីរបស់ខ្លួនជាអសាធារណៈដើម្បីដេញដោលគ្នាទាក់ទងទៅនឹងឈ្មោះសាក្សីដែលភាគីបានលើកឡើងរហូតដល់ម៉ោងជិត១២ថ្ងៃត្រង់ ទើបអង្គជំនុំជម្រះប្រកាសបិទសវនាការបឋមរយៈពេល៤ថ្ងៃនេះជាស្ថាពរ ។

## ៧) បញ្ហាផ្សេងៗ

### ◆ *ថ្ងៃទី១ នៃសវនាការបឋម*

ក្រោយពេលការប្រកាសបើកដំណើរការនីតិវិធីសវនាការបឋមនេះមិនបានប៉ុន្មាននាទីផង សហមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា គឺលោកមេធាវី ស៊ុន អារុណ បានក្រោកឈរឡើងធ្វើការស្នើសុំទៅអង្គសវនាការចំនួនបីចំណុច ៖

ទី១) មេធាវីបានស្នើសុំទៅអង្គសវនាការអនុញ្ញាតឲ្យកូនក្តីរបស់គាត់ គឺ នួន ជា អាចពាក់វ៉ែនតាខ្មៅ និងមួកដើម្បីការពារពន្លឺនិងសីតុណ្ហភាពត្រជាក់នៅក្នុងសាលសវនាការដោយសារ នួន ជា មានបញ្ហាសម្ពាធឈាមឡើងខ្ពស់មិនអាចទ្រាំទ្រនឹងសីតុណ្ហភាពត្រជាក់បាន ។

ទី២) មេធាវីបានស្នើសុំទៅអង្គជំនុំជម្រះថា ឲ្យជួយស្នើសុំទៅការិយាល័យរដ្ឋបាលដើម្បីជួយរៀបចំតុធ្វើការរបស់ខាងសហមេធាវីការពារក្តីឲ្យ នួន ជា ឲ្យបានតុធ្វើការដែលអាចអង្គុយបីនាក់បានដោយមិនចាំបាច់អង្គុយប្រជ្រៀតគ្នានៅពេលឡើងថ្លែងនៅក្នុងពេលមានសវនាការ ។ ព្រោះមេធាវី ដែលការពារក្តីឲ្យ នួន ជា មានគ្នារហូតទៅដល់បីនាក់ ។ ដែលកត្តានេះបានធ្វើឲ្យសហមេធាវីការពារក្តី យល់ថាវាមានភាពលម្អៀងមួយ និងជាការរំលោភចំពោះសិទ្ធិស្មើភាពគ្នានៅក្នុងសវនាការ ។

ទី៣) មេធាវីបានស្នើថាសុំទៅក្រុមប្រឹក្សាជំនុំជម្រះឲ្យ នួន ជា អាចឡើងថ្លែងពីចំណាប់អារម្មណ៍របស់គាត់នៅក្នុងអង្គសវនាការ ។

សូមបញ្ជាក់ថា សំណើរទាំងបីខាងលើរបស់សហមេធាវីការពារក្តីឲ្យ លោក នួន ជា ត្រូវបានទទួលយកដោយលោកប្រធានអង្គជំនុំជម្រះ ។ បន្ទាប់មកប្រធានចៅក្រមក៏បានអនុញ្ញាតឲ្យ នួន ជា ឡើងថ្លែងពីចំណាប់អារម្មណ៍របស់គាត់ ។ ភ្លាមៗក្រោយពេលទទួលបានការអនុញ្ញាតពីលោកប្រធាន ចៅក្រម ជនជាប់ចោទ នួន ជា បានក្រោកឈរឡើងហើយថ្លែងគោរពដោយសភាពគួរសមចំពោះក្រុមប្រឹក្សាជំនុំជម្រះ និងសាធារណជនដែលបានចូលរួមនៅក្នុងសាលសវនាការ ដោយបាននិយាយថា គាត់មិនសប្បាយចិត្តជាមួយនឹងសវនាការនៅក្នុងថ្ងៃនេះទេ ។ នួន ជា បានបន្តទៀតថាគាត់នឹងផ្ទេរសិទ្ធិទៅឲ្យសហមេធាវីការពារក្តីរបស់គាត់ដើម្បីធ្វើការពន្យល់បន្ថែមអំពីការពិត ។ ប៉ុន្តែ មិនទាន់ទាំងបាននិយាយចប់ស្រួលបួលផង នួន ជា ត្រូវបានប្រធានចៅក្រមសម្រេចផ្អាកការថ្លែងរបស់គាត់ ដោយផ្តល់មូលហេតុថា នួន ជា បាននិយាយចាកចេញឆ្ងាយពីប្រធានបទដែលមានសម្រាប់សវនាការបឋម ។ ប៉ុន្តែសហមេធាវីអន្តរជាតិរបស់ នួន ជា បានងើបឡើងនឹងពន្យល់ទៅអង្គជំនុំជម្រះថាតើមូលហេតុអ្វី ទើបបានជា នួន ជា មិនពេញនឹងសវនាការនៅថ្ងៃនេះ ។ ចំពោះការមិនពេញចិត្តនេះ បើតាមសហមេធាវី

ការពារក្តី គឺដោយសារតែសវនាការបឋមនៅក្នុងថ្ងៃនេះគឺមិនមែនសម្រាប់ នួន ជា ទេ ។ ប៉ុន្តែជាសវនាការដែលគេធ្វើឡើងសម្រាប់ពិចារណាទៅលើពាក្យបណ្តឹងរបស់ អៀង សារី ។ ជាងនេះទៅទៀត សាក្សីរបស់ នួន ជា ជាច្រើនត្រូវបានសហចៅក្រមស៊ើបអង្កេតបដិសេធចោល ហើយសាក្សីទាំងអស់នោះមិនត្រូវបានអនុញ្ញាតឲ្យមកផ្តល់សក្ខីកម្មពីបញ្ហានៅភូមិភាគបូព៌ាឡើយ ។ ក្រោយពីសហមេធាវីការពារក្តីរបស់ខ្លួនបានធ្វើការពន្យល់ជូនទៅអង្គជំនុំជម្រះចប់ហើយ នួន ជា បានងើបឈរឡើង ស្នើសុំទៅប្រធានអង្គជំនុំជម្រះដើម្បីចាកចេញពីបន្ទប់សវនាការ ទៅមន្ទីរឃុំឃាំងវិញ ដោយបានបញ្ជាក់ថាគាត់នឹងត្រឡប់មកសវនាការវិញ ដរាបណាអង្គជំនុំជម្រះយល់ព្រមយកសំណើររបស់គាត់មកពិចារណា ។ ប្រធានចៅក្រមក៏បានទទួលយកសំណើររបស់ នួន ជា ដោយអនុញ្ញាតឲ្យត្រឡប់ទៅមន្ទីរ ឃុំឃាំងវិញ ។

ជនជាប់ចោទ ជាបន្តបន្ទាប់បាននាំគ្នាស្នើសុំចាកចេញពីបន្ទប់សវនាការដោយសារមូលហេតុនៃការបង្ហាញពីការមិនសប្បាយចិត្តចំពោះតុលាការ និងដោយសារបញ្ហាសុខភាព ។ ការនេះបានធ្វើឲ្យមានប្រតិកម្មយ៉ាងខ្លាំងពីសំណាក់ចៅក្រមអង្គជំនុំជម្រះ ។ អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទនីមួយៗត្រូវតែមកបង្ហាញខ្លួននៅក្នុងសវនាការជារៀងរាល់ពេលសវនាការ ។ ប្រសិនបើចង់សុំចាកចេញពីបន្ទប់សវនាការ ជនជាប់ចោទត្រូវតែបង្ហាញនូវមូលហេតុជាក់លាក់ដែលអាចទទួលយកបាន ។ ដោយសារតែបញ្ហាអាយុ និងសុខភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះនឹងត្រូវដោះស្រាយបញ្ហានេះបន្ថែមទៀតនៅពេលសវនាការអង្គសេចក្តី ។

សម្រាប់ខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី ការស្នើសុំចាកចេញពីសវនាការរបស់ជនជាប់ចោទនេះគឺជារឿងអយុត្តិធម៌មួយចំពោះជនរងគ្រោះនិងជាការណ៍មួយដែលមិនអាចទទួលយកបាន ។ ពីព្រោះមានជនរងគ្រោះជាច្រើនដែលមានវ័យចាស់ជរាដូចជាជនជាប់ចោទ នៅតែតស៊ូខិតខំអង្គុយនៅក្នុងសាលសវនាការដើម្បីតាមដានដំណើរការនីតិវិធីរបស់តុលាការ ។ ដូច្នេះការស្នើសុំចាកចេញរបស់ជនជាប់ចោទនៅពេលនេះគឺជាការមិនគោរពទៅដល់ជនរងគ្រោះដែលបានទទួលរងការឈឺចាប់ដោយសាររបបគ្រប់គ្រងរបស់ពួកគេ ។

### ◆ ថ្ងៃទី២ នៃសវនាការបឋម

ដោយមិនចង់ឲ្យខាតពេលវេលាច្រើន គ្រាន់តែលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និល ណុន ប្រកាសបើកដំណើរការនីតិវិធីថ្ងៃទី២ភ្លាម ជនជាប់ចោទ នួន ជា បានក្រោកឈរឡើងស្នើសុំទៅអង្គជំនុំជម្រះដើម្បីចាកចេញទៅមន្ទីរឃុំឃាំងវិញដោយបានផ្តល់នូវសម្អាងថា របៀបវារៈនៅថ្ងៃនេះគ្មានការលើកឡើងពីសំណើរដែលគាត់បានដាក់ជូនទៅអង្គសវនាការ ។ ភ្លាមៗ លោកប្រធានចៅក្រមក៏បានសម្រេចតាមការស្នើសុំរបស់ជនជាប់ចោទ នួន ជា ដោយអនុញ្ញាតឲ្យគាត់ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ដោយលើកឡើងថាហេតុផលរបស់ជនជាប់ចោទ នួន ជា អាចទទួលយកបាន ។

### ◆ ថ្ងៃទី៣ នៃសវនាការបឋម

នៅសវនាការថ្ងៃទី៣នេះជនជាប់ចោទ នួន ជា នៅតែបន្តស្នើសុំទៅអង្គជំនុំជម្រះចាកចេញទៅមន្ទីរឃុំឃាំងសារជាថ្មីម្តងទៀត ។ ប្រធានអង្គជំនុំជម្រះបានអនុញ្ញាតគាត់ត្រឡប់ទៅមន្ទីរឃុំឃាំងវិញដូចកាលពីពីរថ្ងៃមុន ។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏សវនាការរយៈពេលបីថ្ងៃកន្លងមកនេះឃើញថាមានតែ ខៀវ សំផន ម្នាក់គត់ដែលមិនបានចាកចេញពីសវនាការនៅពេលដែលដំណើរការនីតិវិធីកំពុងតែបន្ត ។ ហើយសហមេធាវី ស សូវ៉ាន ការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន ក៏ធ្លាប់បានលើកឡើងដែរថា ខៀវ សំផន នឹងព្យាយាមសហការជាមួយនឹងតុលាការដើម្បីរកការពិតដែលទន្ទឹងរង់ចាំជាយូរមកនេះ ។

### ◆ ថ្ងៃទី៤ នៃសវនាការបឋម

ក្នុងចំណោមសវនាការទាំងបួនថ្ងៃគឺមានតែសវនាការថ្ងៃទី៤នេះទេ ដែលជនជាប់ចោទទាំងបួនរូប នៅអង្គុយក្នុងសាលសវនាការរហូតដល់ពេលបញ្ចប់ដំណើរការនីតិវិធីដោយមិនមានការស្នើសុំចាកចេញពីអង្គសវនាការ ។ សវនាការបន្តទៀតនឹងត្រូវធ្វើឡើងជាអសាធារណៈ ក្រោយពីការប្រកាសរបស់អង្គជំនុំជម្រះ អ្នកដែលចូលរួមទស្សនាការជំនុំជម្រះនេះក៏បានត្រឡប់ទៅផ្ទះរបស់គេវិញរៀងៗខ្លួន ប៉ុន្តែមិនដឹងថាដោយសារបញ្ហាបច្ចេកទេស ឬយ៉ាងណា ទើបខាងមន្ត្រីផ្នែកកិច្ចការសាធារណៈបានប្រកាសឲ្យអ្នកចូលរួមចូលក្នុងសាលសវនាការវិញ ដោយប្រកាសថាសវនាការនឹងត្រូវធ្វើជាសាធារណៈ ។ ក្រោយពេលដែលចូលទៅដល់

សាលសវនាការហើយ គូភាគីទាំងអស់ដែលមានវត្តមាននៅក្នុងសាលសវនាការមានទឹកមុខហាក់បីដូចជាចម្លែក ។ មិនមានឮសំឡេងចេញពីបន្ទប់សវនាការអ្វីទាំងអស់ ។ ក្រោយមកទើបខាងមន្ត្រីផ្នែកកិច្ចការសាធារណៈប្រកាសថា សវនាការនៅពេលនោះត្រូវធ្វើជាអសាធារណៈ ដូច្នេះសូមឲ្យអ្នកចូលរួមទស្សនាទាំងអស់ចេញពីសាលសវនាការវិញ ។ នេះប្រហែលជាមកពីបញ្ហាមន្ត្រីផ្នែកកិច្ចការសាធារណៈទទួលព័ត៌មានមិនច្បាស់ពីខាងអង្គជំនុំជម្រះ ។

## ៨) សន្និដ្ឋាន

ពាក់ព័ន្ធនឹងការពិភាក្សាដេញដោលផ្ទាល់មាត់លើអញ្ញត្រកម្មស្តីពីគោលការណ៍មិនអាចកាត់ទោសពីរដងចំពោះបទល្មើសតែមួយ មេធាវីការពារក្តីឲ្យ អៀង សារី បានលើកឡើងពីមូលដ្ឋានច្បាប់ពីរយ៉ាងរឹងមាំដើម្បីរារាំងការចោទប្រកាន់ អៀង សារី ចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ទីមួយគឺគោលការណ៍អាជ្ញាអស់ជំនុំដែលមានចែងក្នុងមាត្រា១២នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ ដែលចែងថា "...ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែលនោះ ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ" និងទីពីរ គោលការណ៍អាជ្ញាអស់ជំនុំដែលមានចែងក្នុងមាត្រា១៤ អនុវិធានទី៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលចែងថា "គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយ ចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មរបស់រដ្ឋនីមួយៗរួចហើយ" ។ ក្នុងការឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារឲ្យ អៀង សារី ខាងភាគីសហព្រះរាជអាជ្ញាមានមូលដ្ឋានច្បាប់តិចតួចបំផុត ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាព្យាយាមលើកពីបញ្ហាមួយចំនួនដែលរំលោភលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះទោសដោយត្រឹមត្រូវនិងយុត្តិធម៌ ដែលការរំលោភនេះអាចនាំឲ្យមោឃភាពលើសាលក្រមកាត់ទោស អៀង សារី ដោយតុលាការប្រជាជនបដិវត្តក្នុងឆ្នាំ១៩៧៩ ។ ចំណែកសហមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានព្យាយាមធ្វើការបដិសេធចោលនូវសេចក្តីសម្រេចរបស់តុលាការប្រជាជនបដិវត្តឆ្នាំ១៩៧៩ ដោយសារតែសេចក្តីសម្រេចនេះមិនបានឆ្លើយតបទៅនឹងសិទ្ធិទទួលបានសំណងជំងឺចិត្តរបស់ជនរងគ្រោះដែលបណ្តាលមកពីអំពើល្មើសនោះឡើយ ។ មេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក៏បានបន្ថែមថា ការកាត់ទោសដោយតុលាការឆ្នាំ១៩៧៩ មិនមែនជាឧបសគ្គរារាំងក្នុងការនាំយក អៀង សារី មកចោទប្រកាន់ចំពោះមុខតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនោះទេ ព្រោះឧក្រិដ្ឋកម្មដែលបានកើតឡើងវាមានលក្ខណៈធ្ងន់ធ្ងរ ។

នៅក្នុងបញ្ហារឿងដែលទាក់ទងទៅនឹងអញ្ញត្រកម្មស្តីពីការលើកលែងទោស និងអនុគ្រោះទោសត្រូវបានគូភាគីនៅក្នុងអង្គសវនាការបានធ្វើការជជែកដេញដោលនិងលើកឡើងនូវហេតុផលជាច្រើនដើម្បីព្យាយាមធ្វើការពន្យល់ទៅចៅក្រមឲ្យយល់ស្របទៅតាមការអះអាងរបស់ខ្លួន ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយក៏អ្នកជំនាញ និងអ្នកចូលរួមភាគច្រើនមើលឃើញថា ការលើកឡើងរបស់ខាងភាគីសហមេធាវីការពារក្តីឲ្យជនជាប់ចោទបានផ្តោតទៅលើច្បាប់ជាតិនិងអន្តរជាតិ រួមទាំងអនុសញ្ញាអន្តរជាតិមួយចំនួនដើម្បីធ្វើជាអំណះអំណាងរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ។ អ្នកវិភាគជាច្រើនបាន មើលឃើញជាមុនហើយថា ទាក់ទងទៅនឹងបញ្ហាលើកលែងទោសចំពោះជនជាប់ចោទ អៀង សារី កាលពីឆ្នាំ១៩៩៦ ដោយព្រះមហាក្សត្រនេះ បានធ្វើឲ្យភាគីមេធាវីការពារក្តីរបស់ អៀង សារី មានមូលដ្ឋានច្បាប់ច្រើនក្នុងការតវ៉ានៅក្នុងតុលាការ ។ បើទោះបីជាយ៉ាងនេះក្តី មានការបកស្រាយយ៉ាងច្រើនពីសំណាក់សហព្រះរាជអាជ្ញាចំពោះអានុភាពនៃព្រះរាជក្រឹត្យទៅលើបទល្មើសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលមានលក្ខណៈជាអន្តរជាតិ ។ ការលើកឡើងរបស់សហព្រះរាជអាជ្ញាគឺហាក់បីដូចជារឹងមាំខ្លាំងត្រង់ថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាតុលាការអន្តរជាតូបនីយកម្ម ដូច្នេះការលើកលែងទោសដោយច្បាប់ជាតិមិនអាចហាមឃាត់មិនឲ្យនាំយកជនដែលប្រព្រឹត្តបទល្មើសជាធ្ងន់ធ្ងរដែលមានលក្ខណៈអន្តរជាតិបានឡើយ ។ ជាពិសេសច្បាប់អន្តរជាតិមិនទទួលស្គាល់ការលើកលែងទោសដល់អំពើប្រល័យពូជសាសន៍នោះទេ ។ ម្យ៉ាងវិញទៀត បើក្រឡេកមើលការលើកឡើងរបស់មេធាវីការពារក្តីរបស់ជនជាប់ចោទឃើញថា គេមិនអាចយកអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ មកធ្វើជាគោលដើម្បីធ្វើ

ការចោទប្រកាន់ចំពោះ អៀង សារី បានឡើយ ដោយសារតែនៅពេលដែលឧក្រិដ្ឋកម្មកើតឡើងនៅពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ កម្ពុជាមិនទាន់បានចូលជាសមាជិកអនុសញ្ញានេះនៅឡើយទេ ។ លើសពីនេះទៀត សហមេធាវី អៀង សារី នៅតែទទូចថា អនុសញ្ញានេះមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចយកមកអនុវត្តចំពោះប្រទេសកម្ពុជានោះទេ បើទោះបីជាខាងភាគីសហព្រះរាជអាជ្ញាបានលើកឡើងផ្ទុយពីនេះក៏ដោយ ។ ការបកស្រាយរបស់ភាគីទាំងសងខាងនឹងក្លាយទៅជាកម្មវត្ថុនៃការពិចារណារបស់អង្គជំនុំជម្រះថាតើអនុសញ្ញាទីក្រុងហ្សឺណែវនេះអាចត្រូវបានយកមកប្រើនៅចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានឬមិនបាន ។ សេចក្តីសម្រេចនឹងចេញនូវពេលក្រោយ ។

ចំពោះការទាញហេតុផលដោយផ្ទាល់មាត់លើអញ្ញត្រកម្មស្តីពីអាជ្ញាយុកាលនៃបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មេធាវីរបស់ជនជាប់ចោទ អៀង សារី បានលើកឡើងថា ការបន្តអាជ្ញាយុកាល៣០ឆ្នាំចំពោះបទល្មើសដូចបានកំណត់ក្នុងមាត្រា៣ថ្មីនៃច្បាប់ស្តីពីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម គឺជាការរំលោភលើគោលការណ៍មិនប្រតិសកម្មចំពោះបទល្មើសព្រហ្មទណ្ឌ និងគោលការណ៍សិទ្ធិទទួលបានការអនុវត្តស្មើគ្នាចំពោះមុខច្បាប់ ព្រោះដោយសារអាជ្ញាយុកាលដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានផុតរលត់ក្នុងរយៈពេល១០ឆ្នាំ គិតចាប់រាប់ពីរយៈពេលដែលបទល្មើសបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ មេធាវីអះអាងថា អៀង សារី មិនអាចត្រូវបានកាត់ទោសដោយច្បាប់ដែលផុតអាជ្ញាយុកាលនេះទេ ។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានលើកឡើងថា ការពន្យារអាជ្ញាយុកាល ដោយមាត្រា៣ថ្មីនៃច្បាប់ស្តីពីបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនបានរំលោភលើគោលការណ៍មិនប្រតិសកម្មចំពោះបទល្មើសព្រហ្មទណ្ឌឡើយ ពីព្រោះថា អាជ្ញាយុកាលដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានព្យួរដោយសារប្រទេសកម្ពុជាមានសង្គ្រាមស៊ីវិលចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៧ ដែលវាធ្វើឲ្យមានការរារាំងដល់ការស៊ើបអង្កេតដើម្បីចោទប្រកាន់ទៅលើជនជាប់ចោទ ។

ឃើញថាបញ្ជីឈ្មោះសាក្សីមានការតវ៉ាជាច្រើនពីសំណាក់ភាគីជនជាប់ចោទ ដោយអះអាងថាសាក្សីដែលមាននៅក្នុងបញ្ជីឈ្មោះភាគច្រើនជាសាក្សីដែលមកពីខាងភាគីសហព្រះរាជអាជ្ញា ចំណែកឯខាងភាគីជនជាប់ចោទមានតែចំនួនមួយភាគតូចប៉ុណ្ណោះ ។ ជាការពិតតុលាការនេះត្រូវបានបង្កើតឡើងដើម្បីនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យដែលបានធ្វើឲ្យបាត់បង់ជីវិតមនុស្សរាប់សិបម៉ឺននាក់មកកាត់ទោសនៅក្នុងគោលបំណងមួយស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដោយសាររបបនេះក៏ពិតមែន ក៏ប៉ុន្តែដើម្បីធ្វើឲ្យការពិតមួយត្រូវបានលាតត្រដាងនោះចាំបាច់ត្រូវតែមានការ ចូលរួមពីសំណាក់គ្រប់គូភាគីទាំងអស់ ទោះបីជាអ្នកដែលនឹងឡើងមកបង្ហាញពីការពិតនៅសម័យនោះជាបុគ្គលដែលមកពីខាងភាគីជនជាប់ចោទក៏ដោយ ។ បើទោះបីជាយ៉ាងនេះក៏ដោយ ក៏តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមួយនេះមិនមានពេលវេលាច្រើននោះទេ ដោយសារតែអាយុនិងសុខភាពរបស់ជនជាប់ចោទ ។ ការកោះហៅសាក្សីច្រើនពេកក៏នឹងអាចធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីនៅក្នុងរយៈពេលមួយសមរម្យផងដែរ ។ ដូច្នេះចំនួនសាក្សីនេះត្រូវតែមានចំនួនមួយសមរម្យដែលអាចបង្ហាញការពិតផង និងការពារមិនឲ្យមានការរំលោភដល់សិទ្ធិរបស់ជនជាប់ចោទផង ។ ជនរងគ្រោះក៏អំពាវនាវឲ្យមានការជំនុំជម្រះឲ្យបានឆាប់រហ័សដែរ ព្រោះជនរងគ្រោះកំពុងទន្ទឹងរង់ចាំយុត្តិធម៌មួយដែលកើតចេញពីការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នេះ ។

នៅក្នុងសវនាការបឋមនេះ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីបានលើកបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូងផងដែរនូវសំណើជាដំបូងនៃសំណងជំងឺចិត្តនៅក្នុងករណីដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស ។ បើពិនិត្យមើលជារួមឃើញថា នៅក្នុងសវនាបឋមទាំងបួនថ្ងៃនេះ បានដំណើរការទៅមុខយ៉ាងរលូន និងបានទាក់ទាញការចាប់អារម្មណ៍ពីសំណាក់មហាជនទូទៅជាច្រើនឲ្យមកចូលរួមទស្សនានៅក្នុងសាលសវនាការ ។ អ្នកដែលបានមកចូលរួមទស្សនាសវនាការបឋមរយៈពេល៤ថ្ងៃនេះ មានចំនួនសរុបរហូតដល់ទៅ២,៦៩៦នាក់ ។ សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះគឺទទួលបានចំណាប់អារម្មណ៍ខ្លាំងពីប្រជាពលរដ្ឋកម្ពុជាទាំងក្នុងនិងក្រៅប្រទេស ។ ***ពិនិត្យនិងផ្ទៀងផ្ទាត់ដោយ ដី ទេវិទ្ធិ***



អៀង សារី (រូបថតកណ្តាល ពាក់អាវខ្មៅ) និង អៀង ធីរិទ្ធ (រូបខាងឆ្វេង) ជាមួយគណៈប្រតិភូចិន ។ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨ (ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ប៉ុល ពត (រូបខាងស្តាំ) ស្វាគមន៍គណៈប្រតិភូចិន វ៉ាង ដុងស៊ីង (រូបខាងឆ្វេង) និងគណៈប្រតិភូ នៅឯព្រលានយន្តហោះ ពោធិ៍ចិនតុង ។ ខាងក្រោយអ្នកទាំងពីរ គឺ ខៀវ សំផន និង នួន ជា (ប្រភព : បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា

*ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥*

*ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨*

*អ៊ីម៉ែល : dccam@online.com.kh*

*គេហទំព័រ : www.dccam.org ឬ www.cambodiatribunal.org*



*គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ*

*John D. and Catherine T. MacArthur Foudation ។*




**ឌី សុជាតា**

**សុជាតា** ជានិស្សិតថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ សិក្សាជាភាសាអង់គ្លេស នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**គីម ម៉ារីយ៉ាន**

**ម៉ារីយ៉ាន** បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកច្បាប់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ម៉ារីយ៉ាន ជាអតីតជ័យលាភីថ្នាក់ជាតិនៅក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



**លឹម ជ័យទត្ត**

**ជ័យទត្ត** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ជ័យទត្ត សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។



**ចាន ប្រាថ្នា**

**ប្រាថ្នា** ទទួលបានបរិញ្ញាប័ត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ ប្រាថ្នា សព្វថ្ងៃកំពុងត្រៀមប្រឡងសិក្សាវិជ្ជាជីវៈមេធាវី នៅកម្ពុជា ។




មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិ ខែមិថុនា ឆ្នាំ២០១១